លេខ ៣ ថ្ងៃ ៤ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥០៤
ត្រូវនឹងថ្ងៃទី ១ ខែកក្កដា គ.ស. ១៩៦១

B-4
D-05
N° 979

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្តី ប្រចាំត្រីមាស

## នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌល កម្ពុជរដ្ឋ

# LA LUMIERE BOUDDHIQUE

## REVUE TRIMESTRIELLE
## DE
## L'ASSOCIATION DES BOUDDHISTES-CENTRE DU CAMBODGE

...រជាតិ
...ាន

N° 3.— Samedi 1er Juillet 1961

I.K-36
1961-3

សៅរ៍ ថ្ងៃ ៤ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥០៤
ត្រូវនឹងថ្ងៃទី ១ ខែកក្កដា គ.ស. ១៩៦១

# ពន្លឺពុទ្ធចក្រ

## ទស្សនាវដ្ដី ប្រចាំត្រីមាស

នៃ

## ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ

---

# LA LUMIERE BOUDDHIQUE

REVUE TRIMESTRIELLE

DE

L'ASSOCIATION DES BOUDDHISTES-CENTRE DU CAMBODGE

N° 3.— Samedi 1er Juillet 1961

អាន « ពន្លឺពុទ្ធចក្រ » នាំឲ្យបានដល់នូវសិរីសួស្តី ដល់ខ្លួនផង ដល់គ្រួសាររបស់ខ្លួនផង ដល់សង្គមមនុស្សផង ។

ក្នុង « ពន្លឺពុទ្ធចក្រ » មានចុះអត្ថបទសុទ្ធសឹងមានសារប្រយោជន៍ទូលំទូលាយ ។

អត្ថបទ « ពន្លឺពុទ្ធចក្រ » សុទ្ធតែជាស្នាដៃរបស់អ្នកប្រាជ្ញយ៉ាងជំនាញ ៗ បានរៀបរៀង ។

ក្នុងគ្រួសារនីមួយ ៗ គួរមាន « ពន្លឺពុទ្ធចក្រ » ជាកល្យាណមិត្ត ។

« ពន្លឺពុទ្ធចក្រ » បណ្ដុះនាំនូវសន្តិធម៌ក្នុងបណ្ដាមនុស្សជាតិ ។


ចាងហ្វាងនៃការផ្សាយ : រ៉ាយ-ល្មុត

បណ្ណាធិការ : ណង-លន់

ទីសំណាក់ការបណ្ដោះអាសន្ន : វត្តឧណ្ណាលោមភ្នំពេញ

Directeur de publication : Ray-Lomuth
Gérant : Nong-Lonn
Siège provisoire : Watt Unnalom Phnom-Penh Cambodge .

# ពន្ធ័ពុទ្ធបក្រ

| មាតិកាពឿង | ទំព័រ |
|---|---|
| – អំពីការបង្កើតគណៈកម្មាធិការខេត្ត-ស្រុកឃុំ រៀបរៀងដោយលោក ក៉ាយ - ល្មុត . . . | ១ |
| – គោលនៃពុទ្ធសាសនា រៀបរៀងដោយព្រះពុទ្ធវង្ស គឹម - ទូរ . . . | ៥ |
| – សេចក្ដីថ្លែងការណ៍នៃព្រះពោធិវង្ស ហា - តាត រៀបរៀងដោយលោក ហ៊ុយ-អ៊ូច . . . | ១៣ |
| – អដ្ឋសតតណ្ហាបញ្ហា រៀបរៀងដោយព្រះខេមមុនីព្រាជ្ញ - ប៉ុល . | ២០ |
| – ការសំដែងធម៌ រៀបរៀងដោយព្រះឃោសធម្មកៅ - ស៊ឹម | ២៤ |
| – ឆ្លើយបញ្ហា ៣ យ៉ាងរបស់លោក គ្រឿង-ឈរលក្ខណ៍ រៀបរៀងដោយព្រះពុទ្ធវង្ស គឹម-ទូរ | ២៨ |
| – ប្រវត្តិសង្ខេបនៃនាងយ៉ានដឹងជាតិ រៀបរៀងដោយព្រះពុទ្ធវង្ស គឹម-ទូរ . . . | ៣០ |
| – ដំណឹងផ្សេងៗ រៀបរៀងដោយលោក ក៉ាយ ល្មុត . . . | ៣៤ |
| – នាមអស់លោកដែលបានសុំចូលជាសមាជិកសមាជិកានៃពុ.ម.កា. ក្នុងឆ្នាំ ១៩៦១ . . . | ៣៩ |

# អំពីការបង្កើតគណៈកម្មាធិការខេត្ត-ស្រុក ឬឃុំ

របស់

## ពុទ្ធិកសមាគម មជ្ឈមណ្ឌល កម្ពុជរដ្ឋ

យើងបានទទួលដំណឹង ដោយមានសេចក្ដីជ្រះថ្លាជាទីបំផុតថា មានពុទ្ធមាមកជនជាច្រើន ទាំងបព្វជិត ទាំងគ្រហស្ថ ក្នុងព្រះរាជាណាចក្រចង់រួបរួមគ្នាបង្កើតសាខានៃ ពុ.ម.ក. នៅតាមតំបន់នោះៗ តែពុំជ្រាបជាច្បាស់លាស់នូវរបៀបចាត់ការយ៉ាងណាខ្លះ ដើម្បីបង្កើតសាខានោះ ។

យើងសូមជូនពត៌មាន ក្នុងរឿងនេះ ដូចតទៅ ៖

ជាដំបូង យើងសូមរំលឹកនូវគោលការណ៍ធំៗខ្លះ ដែលមានចែងក្នុងលក្ខន្តិកៈនិងបទបញ្ជានៃ ពុ.ម.ក. មានសេចក្ដីសំខាន់ៗ ថា ៖

គណៈកម្មាធិការនាយកនៃ ពុ.ម.ក. នៅទីក្រុងភ្នំពេញ ត្រូវប្រគល់អំណាចខ្លះរបស់ខ្លួន ទៅគណៈកម្មាធិការខេត្ត-ស្រុកនិងឃុំ ; គណៈកម្មាធិការនាយកជាអ្នកតែងតាំងគណៈកម្មាធិការខេត្ត-ស្រុក និង ឃុំ សម្រាប់មួយឆ្នាំ ។ គណៈកម្មាធិការខេត្ត-ស្រុកនិងឃុំមានសមាសភាពដូចតទៅនេះ ៖

- នាយកគណៈកម្មាធិការ ១ រូប
- លេខាធិការ ១ –
- ហេរញ្ញិក ១ –
- ស្នងការ ២ – យ៉ាងតិច ។

តំណែងរបស់នាយគណៈកម្មាធិការនិងហេរញ្ញិក អាចផ្ដុំនៅលើមនុស្សមួយរូបបាន ។ ប្រសិនបើមានតំណែងសមាជិកនៃគណៈកម្មាធិការខេត្ត-ស្រុកឬឃុំណាមួយទំនេរ, សមាជិកដទៃទៀតនៃគណៈកម្មាធិការត្រូវជូនឈ្មោះបេក្ខជនមួយរូប ទៅគណៈកម្មាធិការនាយក (ភ្នំពេញ) ដើម្បីតែងតាំងជំនួស ។ មុខការទាំងឡាយរបស់សមាជិកគណៈកម្មាធិការខេត្ត-ស្រុកនិងឃុំ ជាមុខការដែលត្រូវកាន់កាប់ដោយនត្ថភាព (គឺឥតមានបៀវត្សរ៍ទេ), ប៉ុន្តែសមាជិកនេះអាចសុំឲ្យសងនូវចំណាយទាំងឡាយ ដែលខ្លួនចេញក្នុងប្រយោជន៍សមាគមបាន ក្រោយសេចក្ដីយល់ព្រមរបស់គណៈកម្មាធិការរបស់ខ្លួន ។

នាយគណៈកម្មាធិការខេត្ត-ស្រុកនិងឃុំ មានភារៈចាត់ចែងការតាមសេចក្ដីសម្រេចរបស់គណៈ

កម្មាធិការនាយក និងតាមគោលបំណងនិងកម្មវត្ថុចំនួន ៥ ជាដើមរបស់ ពុ.ម.ភា. គឺ ៖

១| ឧបត្ថម្ភពួកសមាជិក ក្នុងការយកចិត្តទុកដាក់ធ្វើតាម និងក្នុងការប្រតិបត្តិត្រឹមត្រូវតាមពុទ្ធោវាទ ;

២| ប៉ុនប៉ងធ្វើឲ្យមានឯកភាព, សាមគ្គីភាពនិងភាតរភាពរវាងពុទ្ធមាមកជន ;

៣| ផ្សាយនូវអនុត្តរធម៌របស់ព្រះសម្ពុទ្ធ ;

៤| ចាត់ចែងធ្វើសកម្មភាព ខាងប្រជាសង្គ្រោះ, ការសិក្សា, វប្បធម៌ និងកិច្ចការដទៃទៀតជាមនុស្សធម៌

៥| ខំប្រឹងធ្វើការប៉ុនប៉ងឲ្យមានសន្តិភាព និងសុខដុមរមនាមនុស្សជាតិ, ឲ្យមានសុភមង្គលចំពោះសត្វ-លោក, រួបរួមនិងអង្គការដទៃទៀតដែលមានគោលបំណងដូចគ្នា ។

រីឯកិច្ចការដទៃទៀតរបស់គណៈកម្មាធិការខេត្ត-ស្រុកនិងឃុំនោះ មានចែងសព្វគ្រប់នៅប្រការ ២៤,២៥, ២៦,២៧ នៃលក្ខន្តិកៈស្រាប់ ដែលយើងពុំអាចដកស្រង់មករៀបរាប់ឲ្យសព្វគ្រប់ ក្នុងទីនេះបាន ។

## អំពីការបង្កើតគណៈកម្មាធិការខេត្ត-ស្រុកនិងឃុំ

បើពុទ្ធមាមកជន ជាបព្វជិតក្តី ជាគ្រហស្ថក្តី មានប្រាថ្នាចង់បង្កើតសាខានៃ ពុ.ម.ភា. នៅតំបន់ណាមួយ នោះ ត្រូវប្រតិបត្តិតាមទម្រង់ការដូចតទៅ ៖

ជាដំបូង សូមឲ្យមានអ្នកផ្តើមគំនិតមួយរូប ឬច្រើនរូប ។ អ្នកទាំងនេះគប្បីខ្វល់ខ្វាយធ្វើអត្ថាធិប្បាយឲ្យក្បោះក្បាយពន្យល់ពុទ្ធបរិស័ទផងគ្នាឲ្យយល់ច្បាស់ នូវប្រយោជន៍របស់ ពុ.ម.ភា. ដូចមានគោលបំណងដែលចារិកខាងលើស្រាប់ ។ បន្ទាប់តមក សូមឲ្យណាត់កាលបរិច្ឆេទនៃការជួបជុំគ្នា នៅកន្លែងណាមួយ មានសាលានៅក្នុងវត្តណាមួយជាដើម ។ លុះសាធុជនបានអញ្ជើញមកជួបគ្នាកុះករហើយ អ្នកផ្តើមគំនិតត្រូវថ្លែងការណ៍តាមគួរដល់ការ ស្រេចហើយប្រកាសសុំសន្និបាតឲ្យរៀបចំក្រុមអភិបាលបណ្តោះអាសន្នមួយ ប្រកបដោយសមាសភាពដូចតទៅ ៖

ឧបាសក ឬ ឧបាសិកា ដែលចាស់ជាងគេ ១ រូបឲ្យធ្វើជាប្រធាន

– ដ – ដែលចេះសរសេរអក្សរ ១ រូបឲ្យធ្វើជាលេខាធិការ

– ដ – – ២ រូបឲ្យធ្វើជាអ្នកជំនួយ ។

ក្រុមអភិបាលបណ្តោះអាសន្ននេះ ត្រូវចាត់ការបោះឆ្នោតជ្រើសតាំងសមាជិកនៃគណៈកម្មាធិការ ( ខេត្តឬ

ស្រុក ឬ ឃុំតាមលក្ខណៈនៃសន្និបាត ) ។ ត្រូវសរសេរលើក្ដារខៀន នូវនាមបេក្ខជន (បេក្ខជន គប្បីជា ឧបាសក ឬ ឧបាសិកា ) ស្រេចហើយត្រូវចាត់ការចែកសន្លឹកឆ្នោត ( យកក្រដាសសតាមបាន ) ជូនទីប្រជុំ ។ ក្នុងបណ្ដាបេក្ខជនទាំងនេះ អ្នកបោះឆ្នោតត្រូវសរសេរលើសន្លឹកឆ្នោតនូវនាមបេក្ខជនចំនួន ៥ យ៉ាងតិច ដែលខ្លួនស្រឡាញ់ ហើយយកទៅដាក់ក្នុងហិបដែលតម្កល់ទុកប្រចាំការនេះ ។

ក្រោយដែលបានសួរបញ្ជាក់ហើយឃើញថា គ្មានអ្នកបោះឆ្នោតទៀតទេ, ក្រុមអភិបាលបណ្ដោះអាសន្ន ត្រូវចាប់រាប់ចំនួនឆ្នោតរួចហើយត្រូវប្រកាសនាម ដែលមានចុះក្នុងសន្លឹកឆ្នោតនោះ អ្នកជំនួយត្រូវគូស ចំណាំទៅលើក្ដារខៀនតាមនាមនីមួយ ៗ ស្រេចហើយទើបរាប់ចំនួនសម្លេងដែលឆ្លើយទៅលើនាមបេក្ខជន នីមួយ ៗ ។ ក្នុងបណ្ដាបេក្ខជនដែលបានឆ្នោតច្រើនជាងគេនោះ ប្រធានត្រូវប្រកាសនាមចំនួនយ៉ាងតិច៥ ថា បានទទួលជ្រើសតាំងជាសមាជិកនៃគណៈកម្មាធិការ ( ខេត្ត ឬស្រុក ឬ ឃុំ ) ហើយ ។

ប្រធាននៃក្រុមអភិបាលបណ្ដោះអាសន្នត្រូវហៅឈ្មោះអ្នកជាប់ឆ្នោតឲ្យមកបង្ហាញខ្លួន ចំពោះសន្និបាត ហើយប្រកាសថា តាមគោលការណ៍អ្នកជាប់ឆ្នោតទាំងឡាយ ត្រូវប្រជុំគ្នាភ្លាមហើយសម្រុះសម្រួលគ្នាកំណត់ សមាសភាពនៃគណៈកម្មាធិការ ហើយជំរាបសន្និបាតភ្លាមពីសមាសភាពនេះ ក្នុងពេលប្រជុំនោះ; តែបើ កាលៈទេសៈបណ្ដាលមិនឲ្យធ្វើដូច្នេះបាននោះ ក្នុងបណ្ដាអ្នកជាប់ឆ្នោត សូមឲ្យមានម្នាក់ប្រកាសជំរាបសន្និបាត អំពីដំណើរនេះ, បើដូច្នោះអ្នកដែលជាប់ឆ្នោតមួយរូប ឬ ច្រើនរូបត្រូវផ្ដើមគំនិតអញ្ជើញអ្នកជាប់ឆ្នោតទាំងអស់ មកប្រជុំក្នុងកំឡុង ៧ ថ្ងៃទៅ ដើម្បីសម្រុះសម្រួលគ្នារៀបចំសមាសភាពនៃគណៈកម្មាធិការ, សមាសភាព នេះត្រូវផ្សាយឲ្យមហាជនដឹង មានបិទផ្សាយនៅកន្លែងដែលធ្វើសន្និបាតនោះជាដើម ។ បើមានការ ខ្វែងគំនិតគ្នា ក្នុងរឿងរៀបចំសមាសភាពនេះ សមាជិកដែលជាប់ឆ្នោតនោះ ត្រូវប្រើរបៀបបោះឆ្នោតសម្ងាត់ ។

អំពីកិច្ចការដូចចែងខាងលើ ត្រូវធ្វើកំណត់ហេតុជាពីរច្បាប់បញ្ជូនទៅគណៈកម្មាធិការនាយក នាទីក្រុង ភ្នំពេញ ( ទីស្នាក់ការបណ្ដោះអាសន្នទៅវត្តឧណ្ណាលោម ) ។ គណៈកម្មាធិការនាយកក្រោយការឲ្យសេចក្ដីយល់ ព្រមនឹងត្រឡប់កំណត់ហេតុមួយច្បាប់មកគណៈកម្មាធិការខេត្ត - ស្រុក - ឬឃុំនោះ ៗ វិញ ទុកជាឯកសារគោល ព្រមទាំងប្រដាប់ប្រដាសព្វគ្រប់សម្រាប់គណៈកម្មាធិការប្រើការ ។ គណៈកម្មាធិការដែលកើតឡើងជា ដំបូងដូចរៀបរាប់ខាងលើត្រូវបានឈ្មោះថា គណៈកម្មាធិការបណ្ដោះអាសន្នដែលត្រូវមានអាយុមួយឆ្នាំ គិត ពីថ្ងៃបោះឆ្នោតមក ។ គណៈកម្មាធិការបណ្ដោះអាសន្ននេះ ត្រូវទទួលភារៈរៀបចំដំណើរការណ៍របស់ខ្លួនឲ្យ

បានត្រឹមត្រូវទៅតាមលក្ខន្តិកៈនិងបទបញ្ជានៃ ពុ.ម.ក តទៅ ។

សេចក្តីដូចរាយរាប់ទាំងប៉ុន្មានខាងលើនេះ គឺគ្រាន់តែជាគោល ៗ ប៉ុណ្ណោះទេ ; ឯការលម្អិតលម្អន់តូចតាច ដែលអាចមានឡើងថែមពីនេះខ្វះនោះ ស្រេចហើយតែអ្នកផ្តើមគំនិតលៃលកឲ្យបានស្រួលតទៅ ។

គណៈកម្មាធិការនាយកអំពាវនាវសូមមហាឧបាសក - ឧបាសិកា ព្រះតេជព្រះគុណ មេគណ អនុគណ ជាដើមក្នុងព្រះរាជាណាចក្រកម្ពុជរដ្ឋ មេត្តាខ្វល់ខ្វាយជួយផ្តើមគំនិតបង្កើតសាខានៃ ពុ.ម.គ. ឲ្យបានចំនួនច្រើន ដើម្បីឲ្យបទបញ្ញត្តិមាត្រា ៨ នៃរដ្ឋធម្មនុញ្ញយើងដែលថា «ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ» មានពន្លឺរស្មីត្រចះត្រចង់ជាតិយេ្យភាពតទៅ សមទៅតាមគោលបំណងរបស់ ពុ.ម.គ. ពោលគឺ សន្តិភាពក្នុងកម្ពុជរដ្ឋនិងក្នុងពិភពលោកជាដើម ។

គណៈកម្មាធិការនាយក

# គោលនៃពុទ្ធសាសនា

## ធម្មជាតអ្វីដែលហៅថា គោលនៃពុទ្ធសាសនា ?

មុននឹងដោះស្រាយចំណោទនេះ សូមពណ៌នាអំពីជំនឿរបស់មនុស្សទូទៅ ដែលពាក់ព័ន្ធជាប់ទៅលើសាសនាទីមួយៗ ដូចសេចក្ដីបរិយាយដោយសង្ខេបតទៅនេះ ៖

ធម្មតាមនុស្សដែលកើតមកក្នុងលោក រមែងស្រឡាញ់ជីវិត គឺការចង់រស់នៅជាងអ្វីទាំងអស់ ដោយអំណាចសេចក្ដីស្រឡាញ់នោះឯង គឺមិនចង់ឲ្យជីវិតស្លាប់បាត់ទៅវិញទេ មិនចង់ឲ្យមានឧបស័គ្គអ្វីមកប៉ះពាល់ដល់ជីវិត ដែលជាហេតុនាំឲ្យជីវិតវិនាសទៅវិញទេ មិនចង់ឲ្យជីវិតធ្លាក់ចុះកាន់ឋានៈដ៏ថោកទាបទេ គឺចង់ឲ្យជីវិតតាំងនៅដោយយឺនយូរ នឹងដោយថ្លៃថ្នូរតែម្យ៉ាងប៉ុណ្ណោះ ។ ម្យ៉ាងទៀត បើជីវិតពុំព្រមឋិតនៅតាមបំណងរបស់ខ្លួន ឬដោយការឧបត្ថម្ភរបស់ខ្លួនទេ បែរជានឹងឃ្លាតចាកអាយុជីវិតចាស់ ហើយទៅកាន់ជីវិតថ្មីទៀត ក៏នៅតែមានបំណងមិនចង់ឲ្យជីវិតទៅឋិតនៅក្នុងទីដែលរងទុក្ខដ៏ថោកទាប គឺចង់ឲ្យជីវិតទៅប្រតិស្ឋានក្នុងកន្លែងដែលគេសន្មតថាជាទីសប្បាយដោយសុខតែម្យ៉ាងប៉ុណ្ណោះ ។

ដោយមានគោលបំណងដ៏មាំដូចបានពណ៌នាមកខាងលើនេះឯង បានជាមនុស្សទូទៅ តែងមានសេចក្ដីភ័យទុក្ខព្រួយចំពោះការប្រែប្រួលនៃជីវិតរបស់ខ្លួនយ៉ាងក្រៃលែង ម្ល៉ោះហើយក៏ខំស្វះស្វែងរកទីពឹងចំពោះវត្ថុណាមួយ ដែលគេសន្មតថាជាវត្ថុដ៏ស័ក្តិសិទ្ធិផ្សេងៗ ដើម្បីនឹងបានជួយឃុំគ្រងកំដរជីវិត ឲ្យជាទីសង្ឃឹមកក់ក្ដៅទុកចិត្តរបស់ខ្លួន ដោយខ្លាចក្រែងបំណងរបស់ខ្លួនពុំបានសំរេច ព្រោះហេតុនោះ បានជាមនុស្សទូទៅក្នុងលោក បណ្ដោតជំនឿរបស់ខ្លួនទៅភ្ជាប់ក្នុងវត្ថុអ្វីមួយដើម្បីជាបង្អែកនៃជីវិត ។ ជំនឿនោះបើមិនច្រើន ក៏គង់បន្តិចបន្តួចដែរ ដែលគេយល់ឃើញថាជាវត្ថុដ៏ស័ក្តិសិទ្ធិ គួរសង្ឃឹមពឹងពាក់អាស្រ័យ គួរគោរពរាប់អាន ពុំសូវនៅទោលទំនេរ ឥតទីពឹងអ្វីនោះឡើយ ។ ឯវត្ថុដ៏ស័ក្តិសិទ្ធិនោះ គេច្រើននិយមយកលទ្ធិជាប្រពៃណីរបស់បុព្វបុរស សម្រាប់ជាតិទីមួយៗ ដែលគេតែងប្រព្រឹត្តកាន់ខ្ជាប់ ទុកជាជំនឿតៗគ្នាមកកំណត់ហៅថា សាសនា ។ សាសនានោះ មានគតិផ្សេងពីគ្នាក៏មាន ស្រដៀងគ្នាឬត្រូវគ្នាខ្លះក៏មាន តាមមតិរបស់សាស្ដាចារ្យទីមួយ ៗ ដែលប្រឌិតតាមហេតុផលបង្កើតឡើង ដើម្បីប្រដៅបរិស័ទឲ្យមានជំនឿចុះចូលគោរពរាប់អាន ដូចយើងបានឃើញ បានឮមកហើយដែលមានក្នុងលោកសព្វថ្ងៃនេះ ។

សាសនាក្នុងលោក មានច្រើនប្រភេទគឺពិតមែន ប៉ុន្តែបើកំណត់យកសាសនាដែលមានមនុស្សកាន

ច្រើននិយមគោរពរាប់អាន ឃើញមានតែ ៤ ប្រភេទ ដែលគេសំគាល់ថាជាសាសនាធំផុតបណ្ដាប់លើសសាសនាឯទៀតទាំងអស់គឺ ពុទ្ធសាសនា ១ ព្រាហ្មណសាសនា ១ គ្រិស្តសាសនា ១ ឥស្លាមសាសនា ១ ។ ចំណែកខាងសាសនា ២ គឺគ្រិស្តសាសនា នឹងឥស្លាមសាសនា មានសេចក្ដីសំដែងចង្អុលប្រាប់ត្រឹមតែឋាននរក-សួគ៌ ដល់អ្នកដែលប្រព្រឹត្តអំពើអាក្រក់នឹងល្អ ឯខាងព្រាហ្មណសាសនាក៏មានសេចក្ដីចង្អុលប្រាប់ឋាននរក - សួគ៌ រហូតដល់ព្រហ្មផងទៀត ។ សាសនាទាំង ៣ នេះ ប្រដៅដឹកនាំសត្វវិលនៅតែក្នុងវង្វង់លោកនរក លោកសួគ៌ នឹងលោកព្រហ្មប៉ុណ្ណោះឯង មិនអាចដឹកនាំសត្វដែលប្រតិបត្តិតាមឲ្យបានដល់នូវទីបំផុតនៃទុក្ខ ឬឲ្យចេញចាកលោកទាំង ៣ នេះបានឡើយ ។

ពុទ្ធសាសនា ជាសាសនាមានសារៈសំខាន់ជាងសាសនាឯទៀត ដោយហេតុថា ពុទ្ធសាសនានេះមានសេចក្ដីសំដែងចង្អុលប្រាប់នរក-សួគ៌ នឹងព្រហ្ម ដូចសាសនាឯទៀតដែរ ប៉ុន្តែមានគុណវិសេសមួយថ្នាក់ទៀត អាចធ្វើអ្នកប្រតិបត្តិតាមឲ្យបានដល់នូវទីបំផុតនៃទុក្ខឬទីបំផុតនៃលោកទាំង ៣ គឺបានដល់និព្វានដែលជាធម្មជាតមិនមានជាតិ ជរា ព្យាធិ មរណៈ ផងទៀត ឃើញថាពុទ្ធសាសនាមានសេចក្ដីទូលំទូលាយវិសេសជាងសាសនាដទៃពិតមែន ។ ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង ព្រះអង្គមានវិចារណញ្ញាណដ៏ជ្រាលជ្រៅទ្រង់បានពិចារណាការកើតហេតុផលនៃសេចក្ដីសុខនឹងទុក្ខឃើញជាក់ច្បាស់ តាំងអំពីព្រះអង្គឋិតនៅក្នុងឋានៈជាពោធិសត្វមាននាមថា សុមេធបណ្ឌិត ។ សូមពណ៌នាដោយសង្ខេបថា សុមេធបណ្ឌិតនោះ បានពិចារណាឃើញច្បាស់ថា ធម្មតាសង្ខារដែលគុបតែងរូបធម៌នឹងអរូបធម៌ឲ្យកើតមានឡើងក្នុងលោក សុទ្ធសឹងតែមានសភាពជាគូៗ នឹងគ្នាយ៉ាងនេះ កាលបើសេចក្ដីទុក្ខមាន សេចក្ដីសុខជាធម្មជាតផ្ទុយនឹងសេចក្ដីទុក្ខក៏គង់មាន, កាលបើរបស់ក្ដៅមាន ធម្មជាតដ៏ត្រជាក់សម្រាប់លត់នូវកំដៅនោះក៏គង់មាន, កាលបើភ្លើងទាំងបី ៣ មានភ្លើងគឺរាគៈជាដើមមាន ធម្មជាតសម្រាប់លត់នូវភ្លើងនោះ ក៏គង់មាន, កាលបើបាបមាន បុណ្យក៏គង់មាន, កាលបើជាតិ (កំណើត) មាន ធម្មជាតសម្រាប់ធ្វើមិនឲ្យមានជាតិទៀតក៏គង់មាន ។ មិនតែប៉ុណ្ណោះ សុមេធបណ្ឌិត បានពិចារណាដោយសេចក្ដីឧបមាឧបមេយ្យថែមទៀតថា ប្រៀបដូចបុរសម្នាក់ ដើរទៅធ្លាក់ក្នុងរណ្ដៅលាមក ប្រឡាក់ដោយលាមកពាសពេញទាំងខ្លួន បុរសនោះឯង ក្រឡេកមើលអំពីចម្ងាយទៅ ឃើញស្រះបោក្ខរណីមួយឋិតនៅពីខាងមុខ ដេរដាសដោយផ្កាឈូក មានទឹកថ្លាស្អាត, កាលបើបុរសនោះ ឃើញស្រះមានទឹកថ្លាស្អាតយ៉ាងនេះហើយ មិនដើរចុះទៅងូតទឹកស្រះនោះយកមកលាងជម្រះលាមកដែលប្រឡាក់ខ្លួនឲ្យ

ជ្រះស្អាតបាតទេ ក៏មិនមែនជាទោសរបស់ស្រះ គឺជាទោសរបស់បុរសនោះឯង យ៉ាងណាមិញ, អាត្មាអញមានខ្លួនកំពុងប្រឡាក់ដោយមន្ទិល គឺកិលេសយ៉ាងនេះ ទឹកស្រះពោលគឺអមតនិព្វានដែលជាធម្មជាតសម្រាប់លាងជម្រះនូវមន្ទិលគឺកិលេសរបស់សព្វសត្វមាន ប៉ុន្តែបើអាត្មាអញ មិនស្វែងរកទឹកស្រះគឺអមតនិព្វាននោះមកលាងជម្រះមន្ទិលគឺកិលេស ដែលអាស្រ័យនៅក្នុងសន្តានចិត្តឲ្យស្អាតបាតទេ ក៏មិនមែនជាទោសរបស់ទឹកស្រះគឺអមតនិព្វាន គឺជាទោសរបស់អាត្មាអញដោយពិត ក៏យ៉ាងនោះដែរ ។ មួយទៀត ប្រៀបដូចបុរស ដែលត្រូវសត្រូវគឺចោរចោមរោមព័ទ្ធជិតជុំវិញខ្លួន ហើយបំរុងនឹងសម្លាប់ដណ្ដើមយកទ្រព្យសម្បត្តិ ឯផ្លូវសម្រាប់បុរសនោះរត់គេចចេញអំពីកណ្ដាប់ដៃចោរនោះមាន ប៉ុន្តែបើបុរសនោះ មិនរត់គេចចេញទៅតាមផ្លូវនោះទេ ក៏មិនមែនជាទោសរបស់ផ្លូវ គឺជាទោសរបស់បុរសនោះឯង យ៉ាងណាមិញ, អាត្មាអញដែលត្រូវសត្រូវគឺកិលេសចោមរោមរួបរឹតជុំវិញហើយ ឯផ្លូវដ៏ក្សេមជាទីទៅកាន់និព្វាន សម្រាប់រត់គេចចេញអំពីសត្រូវគឺកិលេសមាន ប៉ុន្តែបើអាត្មាអញមិនរត់គេចចេញទៅតាមផ្លូវដ៏ក្សេមគឺនិព្វាននោះទេ ក៏មិនមែនជាទោសរបស់ផ្លូវដ៏ក្សេមគឺនិព្វាន គឺជាទោសរបស់អាត្មាអញដោយពិត ក៏យ៉ាងនោះដែរ ។ មួយវិញទៀត ប្រៀបដូចបុរសដែលត្រូវជម្ងឺ គឺរោគផ្សេង ៗ បៀតបៀនរាងកាយឲ្យឈឺចាប់ជានិច្ចកាល ឯពេទ្យសម្រាប់ព្យាបាលឲ្យជាជម្ងឺមាន ប៉ុន្តែបើបុរសនោះ មិនទៅស្វែងរកពេទ្យនោះឲ្យមកព្យាបាលជម្ងឺរបស់ខ្លួនទេ ក៏មិនមែនជាទោសរបស់ពេទ្យ គឺជាទោសរបស់បុរសនោះឯង យ៉ាងណាមិញ, អាត្មាអញដែលត្រូវជម្ងឺគឺកិលេសបៀតបៀនយ៉ាងនេះ ឯអាចារ្យឬអ្នកប្រាជ្ញដែលជាអ្នកឈ្លាសវៃប៉ិនប្រសប់ក្នុងការព្យាបាលរម្ងាប់នូវជម្ងឺគឺកិលេសមាន ប៉ុន្តែបើអាត្មាអញ មិនទៅស្វែងរកអាចារ្យឬអ្នកប្រាជ្ញនោះ ឲ្យជួយណែនាំពន្យល់ក្នុងការព្យាបាលរម្ងាប់នូវជម្ងឺគឺកិលេសរបស់ខ្លួនទេ ក៏មិនមែនជាទោសរបស់អាចារ្យ ឬអ្នកប្រាជ្ញ គឺជាទោសរបស់អាត្មាអញដោយពិត ក៏យ៉ាងនោះដែរ ។

សុមេធបណ្ឌិត លុះត្រិះរិះគិតប្រកបដោយនេក្ខម្មៈ (ការចេញបួស) ដោយសេចក្ដីឧបមាឧបមេយ្យផ្សេងៗ យ៉ាងនេះហើយ ក៏លះបង់នូវកាមទាំងឡាយហើយ ចេញទៅបួសជាតាបសនៅអាស្រ័យក្នុងព្រៃហិមពាន្ត ខំព្យាយាមធ្វើសមណធម៌អស់កាលមិនយូរប៉ុន្មានក៏បានសម្រេចនូវគុណវិសេសគឺសមាបត្តិ ៨ និងអភិញ្ញា ៥ ក្នុងរវាង ៧ ថ្ងៃប៉ុណ្ណោះ ។ ខាងក្រោយមក សុមេធតាបស បានទទួលពុទ្ធព្យាករណ៍អំពីសំណាក់នៃព្រះពុទ្ធទីបង្ករថា " តាបសនេះ មានសេចក្ដីប្រាថ្នាជាពុទ្ធភូមិ អំណើះពីនេះទៅមុខ នៅចំនួន ៤ អសង្ខេយ្យនឹង ១ សែនកប្បទៀត នឹងបានត្រាស់ជាព្រះពុទ្ធមាននាមថា ព្រះសមណគោតម ក្នុងអនាគត " ។

សុមេធពោធិសត្វ កាលបើបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានសេចក្តីត្រេកអរដោយគិតថា សេចក្តីប្រាថ្នារបស់អាត្មាអញ គង់នឹងបានសម្រេចពុំខាន ៗ ចាប់ដើមអំពីនោះមក សុមេធពោធិសត្វ ប្រឹងព្យាយាមបំពេញបារមីធម៌ទាំង ១០ មានទានបារមីជាដើម ដោយឥតមានសេចក្តីធ្វេសប្រហែស ៗ កាលបើអស់អាយុអំពីនោះទៅក៏អន្ទោលយោនយកកំណើតក្នុងវដ្ដសង្សារអស់កាលជាអនេកជាតិ ទោះបីទៅកើតជាមនុស្សក្តី ជាអមនុស្សមានទេវតាជាដើមក្តី ជាសត្វតិរច្ឆានប្រភេទណាក្តី ព្រះពោធិសត្វមិនគេចអំពីការបំពេញបារមីធម៌ដែរ រហូតដល់មកកើតក្នុងបច្ឆិមជាតិ (ជាតិខាងក្រោយបំផុត) ក្នុងសក្យត្រកូល ដែនសក្កៈ ក្រុងកបិលពស្តុ មានព្រះនាមថា សិទ្ធត្ថៈ ៗ លុះដល់ព្រះជន្មាយុ ២៩ ឆ្នាំ ព្រះសិទ្ធត្ថៈពោធិសត្វ ទ្រង់ស្តេចចេញសាងអភិនេស្ក្រមណ៍ ដោយបានធ្វើទុក្ករកិរិយាអស់ ៦ វស្សា ដើម្បីស្វែងរកពោធិញ្ញាណ ៗ បន្ទាប់ពីនោះមកព្រះអង្គទ្រង់ស្តេចទៅគង់លើរតនបល្ល័ង្កក្រោមអស្សត្ថព្រឹក្ស (ដើមពោធិ៍) ទ្រង់បែរព្រះភក្ត្រឆ្ពោះទៅខាងបុរត្ថិមទិស ត្រង់គយាសីសប្រទេស ជិតស្ទឹងនេរញ្ជរា ៗ នៅទីនោះឯង ក្នុងវេលាបឋមយាម ព្រះ ព្រះបរមពោធិសត្វ ទ្រង់សម្រួលព្រះហឫទ័យរំពឹងពិចារណាកររកពោធិញ្ញាណដោយប្រាជ្ញាញាណដ៏បរិសុទ្ធទៅ ក៏បានរកឃើញវិជ្ជាមួយជាដំបូង ហៅថា បុព្វេនិវាសានុស្សតិវិជ្ជា វិជ្ជានេះកើតឡើងធ្វើឲ្យព្រះអង្គមានព្រះហឫទ័យភ្លឺស្វាងធ្លុះឃើញអតីតខន្ធរបស់ព្រះអង្គនឹងអតីតខន្ធរបស់សព្វសត្វ ដែលធ្លាប់អាស្រ័យនៅក្នុងភពមុនបែបណា ៗ ទ្រង់ឃើញច្បាស់ដោយឥតកំបាំង ៗ លុះចូលក្នុងមជ្ឈិមយាម ព្រះអង្គទ្រង់បានរកឃើញវិជ្ជាមួយទៀត ហៅថា ចុតូបបាតវិជ្ជា វិជ្ជានេះកើតឡើងធ្វើឲ្យព្រះអង្គភ្លឺស្វាងឃើញច្បាស់នូវចុតិនឹងបដិសន្ធិនៃសត្វទាំងឡាយក្នុងលោកទាំង ៣ ។ លុះចូលក្នុងបច្ឆិមយាម ព្រះអង្គទ្រង់បានរកឃើញវិជ្ជាមួយទៀត ហៅថា អាសវក្ខយវិជ្ជា វិជ្ជានេះកើតឡើងធ្វើឲ្យព្រះអង្គភ្លឺធ្លុះឃើញច្បាស់នូវអធ្យាស្រ័យរបស់ព្រះអង្គនឹងសត្វទាំងឡាយ ដែលអស់អាសវកិលេសហើយ ឬមិនទាន់អស់អាសវកិលេសនៅឡើយ ឯវិជ្ជាឯទៀតពីនេះទៀត ក៏ព្រះអង្គរកឃើញជាលំដាប់លំដោយគ្នាដែរ ៗ វិជ្ជាទាំងនេះកើតឡើងក្នុងព្រះហឫទ័យរបស់ព្រះអង្គ នាំឲ្យព្រះអង្គ ភ្លឺស្វាងច្បាស់ថែងដោយឥតមានទើសទាក់កប់កំបាំងនឹងអ្វីឡើយ ប្រៀបដូចទីដែលងងឹតស្លុបដោយផ្ទាំងងងឹតក្នុងរាត្រី មើលអ្វីពុំយល់ គេយកពន្លឺភ្លើងទៅគ្រោលបំភ្លឺត្រង់ទីងងឹតស្លុបនោះ ផ្ទាំងងងឹតនោះក៏ខ្ចាត់បាត់ទៅ គេអាចមើលឃើញវត្ថុអ្វីដែលនៅក្នុងទីនោះបានទាំងអស់, ពុំនោះសោត ប្រៀបដូចភាជនៈអ្វីមួយដែលគេដាក់វត្ថុគ្រប់យ៉ាងក្នុងនោះហើយគ្របជិត មិនអាចមើលដឹងថាមានអ្វីក្នុងនោះទេ ប៉ុន្តែបើគេធ្វើគម្របនោះឲ្យរបើកចេញ

ហើយ គេអាចឃើញរបស់គ្រប់យ៉ាងក្នុងភាជនៈនោះបានទាំងអស់ឥតសល់ចន្លោះ យ៉ាងណាមិញ វិជ្ជាទាំងអស់ដែលព្រះអង្គរកឃើញ ធ្វើឲ្យព្រះអង្គក្ដីច្បាស់ទៃងឥតសល់ចន្លោះ ឬ កំបាំងនឹងប្រាជ្ញាញាណរបស់ព្រះអង្គឡើយ ក៏ដូច្នោះដែរ ។

វិជ្ជាដែលកប់កំបាំងដូចបានពណ៌នាមកខាងលើនោះ គ្មាននរណាមួយក្នុងលោករកឃើញទេ មានតែព្រះអង្គអាចរកឃើញ ហើយប្រកាសប្រាប់ឲ្យលោកទាំងអស់ឃើញតាមព្រះអង្គផង ។ ការរកឃើញដូច្នេះហើយ ទើបគេសន្មតហៅព្រះអង្គថា «ពុទ្ធ» ឬហៅថា «អ្នកត្រាស់ដឹង» ។

ចាប់ដើមតាំងអំពីព្រះអង្គ បានទទួលព្រះបរមនាមថា ព្រះពុទ្ធ ឬថា អ្នកត្រាស់ដឹងមក តែងប្រៀនប្រដៅដឹកនាំសត្វឲ្យប្រព្រឹត្តទៅក្នុងប្រយោជន៍ ៣ យ៉ាងគឺ ទិដ្ឋធម្មិកប្រយោជន៍ (ប្រយោជន៍បច្ចុប្បន្ន) ១ សម្ប-រាយិកប្រយោជន៍ (ប្រយោជន៍បរលោក) ១ បរមប្រយោជន៍ (ប្រយោជន៍ដ៏ប្រសើរគឺព្រះនិព្វាន) ១ បណ្ដាប្រយោជន៍ទាំង ៣ យ៉ាងនោះ ប្រយោជន៍បច្ចុប្បន្ន ព្រះអង្គទ្រង់សំដែងទូន្មានសត្វ ទុកតិចជាងប្រយោជន៍បរលោក ។ ព្រះអង្គទ្រង់សំដែងទូន្មានសត្វ ទុកតិចជាងប្រយោជន៍ គឺនិព្វាន ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ដោយប្រាជ្ញាញាណថា និព្វាន ទើបជាគុណវិសេសអាចញ៉ាំងសត្វឲ្យរួចផុតចាកភ្លើងទុក្ខនឹងភ្លើងកិលេសក្នុងវដ្ដសង្សារបាន ។ ព្រោះហេតុនោះ ពុទ្ធោវាទរបស់ព្រះអង្គដែលទ្រង់ប្រៀនប្រដៅសត្វដោយប្រយោជន៍ ៣ យ៉ាងដូចបានពោលមកហើយនោះ ហៅថាជាគោលនៃពុទ្ធសាសនា ឬពុទ្ធោវាទដែលសំដែងថា:

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។

សេចក្ដីថា «ការមិនធ្វើអំពើអាក្រក់គ្រប់យ៉ាង ១ ការបំពេញកុសលផ្សេងៗ ឲ្យកើតមានឡើង ១ ការធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផូរផង់ចាកគ្រឿងសៅហ្មង ១ ទាំង ៣ នេះ ហៅថាជាគោលនៃពុទ្ធសាសនា» ។

ត្រង់ពុទ្ធោវាទថា ការមិនធ្វើអំពើអាក្រក់គ្រប់យ៉ាងនោះ ជាឱវាទមានសេចក្ដីទូលំទូលាយណាស់ គឺបានដល់សីល ឬសិក្ខាបទទាំងអស់ ជាពុទ្ធបញ្ញត្តិនឹងពុទ្ធានុញ្ញាតដែលមានក្នុងវិនយបិដក ។ ត្រង់ពុទ្ធោវាទថា ការបំពេញកុសលផ្សេងៗ ឲ្យកើតមានឡើងនោះ ជាឱវាទមានសេចក្ដីទូលំទូលាយណាស់ គឺបានដល់ចិត្ត ឬសមាធិចិត្តទាំងអស់ដែលមានក្នុងសុត្តន្តបិដក ។ ត្រង់ពុទ្ធោវាទថា ការធ្វើចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផូរ-ផង់ចាកគ្រឿងសៅហ្មងនោះ ជាឱវាទមានសេចក្ដីទូលំទូលាយណាស់ គឺបានដល់បញ្ញា ឬវិបស្សនាបញ្ញាទាំង

អស់ដែលមានក្នុងអភិធម្មបិដក ។

ន័យមួយទៀត ពុទ្ធសាសនា មានលំអ ៣ ថ្នាក់ គឺសីលចាត់ទុកជាអាទិកល្យាណ (លំអថ្នាក់ខាងដើម) នៃពុទ្ធសាសនា, សមាធិ ចាត់ទុកជាមជ្ឈេកល្យាណ (លំអថ្នាក់កណ្ដាល) នៃពុទ្ធសាសនា, បញ្ញា ចាត់ទុកជាបរិយោសានកល្យាណ (លំអថ្នាក់ខាងចុង) នៃពុទ្ធសាសនា ។

សីលដែលចាត់ទុកជាលំអថ្នាក់ខាងដើមនៃពុទ្ធសាសនា ចែកចេញជា ២ គឺសីល ១ អធិសីល ១ ។

### សីលនិងអធិសីល មានសេចក្ដីផ្សេងគ្នាដូចម្ដេច ?

សីល ៥ ក្ដី សីល ៨ ក្ដី សីល ១០ ក្ដី ហៅត្រឹមតែសីលប៉ុណ្ណោះ ព្រោះថាសីលទាំងនោះ ទោះបីព្រះពុទ្ធកើតឡើងក្ដី មិនទាន់កើតឡើងក្ដី រមែងមានប្រព្រឹត្តទៅ ក្នុងលោកជាធម្មតា ។ សូម្បីក្នុងសម័យដែលព្រះពុទ្ធកើតឡើងហើយ ព្រះពុទ្ធនិងសាវកទាំងឡាយរបស់ព្រះពុទ្ធតែងទូន្មានដឹកនាំមហាជនឲ្យតាំងនៅក្នុងសីលទាំងនោះដែរ ។ ទុកជាក្នុងសម័យដែលព្រះពុទ្ធ មិនទាន់កើតឡើងនៅឡើយ ព្រះបច្ចេកពុទ្ធទាំងឡាយក្ដី សមណព្រាហ្មណ៍ទាំងឡាយ អ្នកប្រព្រឹត្តធម៌ជាកម្មវាទីក្ដី ស្ដេចចក្រពត្តិក្ដី ពោធិសត្វទាំងឡាយក្ដី ក៏គង់តែទូន្មានដឹកនាំមហាជនព្រមទាំងខ្លួនឯង ឲ្យតាំងនៅក្នុងសីលទាំងនោះដែរ ។ ជនទាំងឡាយកាលបើបានបំពេញកុសលកម្មគឺសីលនោះហើយ រមែងបានទទួលនូវសម្បត្តិក្នុងទេវលោកនិងមនុស្សលោក ។ ចំណែកខាងបាតិមោក្ខសំវរសីល ទើបហៅថា អធិសីល ព្រោះថាបាតិមោក្ខសំវរសីលនោះ ជាសីលដ៏ប្រសើរខ្ពង់ខ្ពស់ក្រៃលែងជាងលោកិយសីលទាំងអស់ ដូចព្រះអាទិត្យប្រសើរក្រៃលែងជាងពន្លឺអ្វីទាំងអស់ក្នុងលោក ពុំនោះសោត ដូចភ្នំសិនេរុប្រសើរក្រៃលែងជាងភ្នំទាំងឡាយ ដោយហេតុថា បាតិមោក្ខសំវរ-សីល កើតមានឡើងតែក្នុងសម័យពុទ្ធុប្បាទ គឺក្នុងសម័យដែលមានព្រះពុទ្ធត្រាស់ឡើងក្នុងលោក ក្រៅចាកសម័យពុទ្ធុប្បាទមិនមានសោះឡើយ ។ មែនពិត បាតិមោក្ខសំវរសីល ដែលព្រះពុទ្ធបានបញ្ញត្តតាំងទុកហើយ សត្វដទៃណាមួយ មិនអាចដកពុទ្ធប្បញ្ញត្តិនោះចេញឬតាំងបញ្ញត្តថែមលើពុទ្ធប្បញ្ញត្តិនោះទៀតបានឡើយ មានតែព្រះពុទ្ធទាំងឡាយទេ ទើបអាចដកចេញឬបញ្ញត្តថែមនូវបាតិមោក្ខសំវរសីលឲ្យសមគួរដល់វីតិក្កមទោសនោះៗ បាន ។ ន័យមួយទៀត ក្រៅពីបាតិមោក្ខសំវរសីល, សីលទាំងឡាយដែលសម្បយុត្តដោយមគ្គនិងផល ក៏ហៅថា អធិសីល ផងដែរ ។

ចិត្តសំដៅយកសមាធិចិត្តដែលចាត់ទុកជាលំអថ្នាក់កណ្ដាលនៃពុទ្ធសាសនា ចែកចេញជា ២ គឺចិត្ត ១ អធិចិត្ត ១ ។

ចិត្ត និង អធិចិត្ត មានសេចក្តីផ្សេងគ្នាដូចម្តេច ?

កុសលចិត្ត ៨ ជាកាមាវចរកុសលក្តី សមាបត្តិចិត្ត ៨ ជាលោកិយក្តី រួមហៅត្រឹមតែចិត្តម៉្យាងប៉ុណ្ណោះ ទោះបីក្នុងសម័យពុទ្ធុប្បាទក្តី ក្នុងសម័យមិនមែនពុទ្ធុប្បាទក្តី ការប្រព្រឹត្តិទៅនៃចិត្តទាំងនោះ តែងមានជាប្រក្រតី ។ សូម្បីក្នុងសម័យពុទ្ធុប្បាទ ការទូន្មានដឹកនាំមហាជន របស់ព្រះពុទ្ធនិងសាវកទាំងឡាយរបស់ព្រះពុទ្ធ ក៏គង់តែឲ្យប្រព្រឹត្តទៅក្នុងចិត្តទាំងនោះដែរ ហេតុនោះ ជនទាំងឡាយ កាលបើបានបំពេញកុសលកម្មដោយចិត្តនោះហើយ រមែងបានទទួលនូវសម្បត្តិក្នុងទេវលោកនិងមនុស្សលោក ។ ពុទ្ធសាសនិកអ្នកអាន គប្បីជ្រាបសេចក្តីនេះ តាមន័យដែលបានពោលរួចមកហើយ ក្នុងសីលនោះផងចុះ ។ ចំណែកខាង សមាបត្តិចិត្ត ៨ ដែលជាជើងនៃវិបស្សនា ឬប្រកបដោយវិបស្សនា ទើបហៅថាអធិចិត្ត ព្រោះថា អធិចិត្តនោះ ជាចិត្តប្រសើរឧត្តមក្រៃលែងជាងលោកិយចិត្តទាំងអស់ដូចអធិសីលប្រសើរក្រៃលែងជាងសីលទាំងឡាយដូច្នោះដែរ ។ អធិចិត្តនោះ មានតែក្នុងសម័យពុទ្ធុប្បាទក្រៅចាកសម័យពុទ្ធុប្បាទមិនមានសោះឡើយ ។ ម្យ៉ាងទៀត ក្រៅពីអធិចិត្តនោះចេញ ចិត្តទាំងឡាយដែលសម្បយុត្តដោយមគ្គនិងផល ក៏ហៅថា អធិចិត្ត ផងដែរ ។

បញ្ញាដែលចាត់ទុកជាលំអថ្នាក់ខាងចុងនៃពុទ្ធសាសនា ចែកជា ២ គឺបញ្ញា ១ អធិប្បញ្ញា ១ ។

បញ្ញា និងអធិប្បញ្ញា មានសេចក្តីផ្សេងគ្នាដូចម្តេច ?

កម្មស្សកតាញាណ គឺការដឹងយល់ច្បាស់ថា សត្វទាំងឡាយគ្រប់ប្រភេទ សុទ្ធតែមានកម្មគឺកុសលនិងអកុសលជារបស់ខ្លួន ដែលប្រព្រឹត្តទៅដោយន័យថា « ទានដែលគេឲ្យហើយ រមែងមានផល, ការបូជាធំក្តី តូចក្តី រមែងមានផល, យ៉ាងនេះជាដើម ការយល់ឃើញដូច្នេះ ហៅត្រឹមតែបញ្ញាប៉ុណ្ណោះ ។ ព្រោះថា បញ្ញានោះ ទោះបីក្នុងសម័យដែលមានព្រះពុទ្ធកើតឡើងក្តី មិនទាន់កើតឡើងក្តី រមែងមានប្រព្រឹត្តទៅក្នុងលោកជាធម្មតា ។ សូម្បីក្នុងសម័យដែលព្រះពុទ្ធកើតឡើងហើយ ព្រះពុទ្ធនិងសាវកទាំងឡាយរបស់ព្រះពុទ្ធ តែងទូន្មានដឹកនាំមហាជន ដោយបញ្ញានោះដែរ ។ ទុកជាក្នុងសម័យដែលព្រះពុទ្ធមិនទាន់កើតឡើងនៅឡើយ ព្រះបច្ចេកពុទ្ធទាំងឡាយក្តី សមណព្រាហ្មណ៍ទាំងឡាយអ្នកប្រព្រឹត្តធម៌ជាកម្មវាទីក្តី ស្តេចចក្រព័ត្តិក្តី ពោធិសត្វទាំងឡាយក្តី ក៏គង់តែទូន្មានដឹកនាំមហាជន ដោយបញ្ញានោះដែរ ។ ព្រោះហេតុនោះ ជនទាំងឡាយ កាលបើបានបំពេញកុសលកម្ម ដោយបញ្ញានោះហើយ រមែងបានទទួលនូវសម្បត្តិក្នុងទេវលោកនិងមនុស្សលោក ។

ចំណែកខាង វិបស្សនាញាណ គឺញាណដែលកំណត់ដោយការពិចារណាឃើញច្បាស់ថា សង្ខារទាំងឡាយ សុទ្ធតែលុះនៅក្នុងអំណាចនៃត្រៃលក្ខណ៍ ទើបហៅថា អធិប្បញ្ញា ព្រោះថាអធិប្បញ្ញានោះ ជាធម្មជាតិប្រសើរឧត្តមក្រៃលែងជាងលោកិយបញ្ញាទាំងអស់ ដូចជាអធិសីលនឹងអធិចិត្ត ប្រសើរក្រៃលែងជាងសីលនឹងចិត្តទាំងឡាយ ដូច្នោះដែរ ។ អធិប្បញ្ញានោះ បើវៀរចាកសម័យពុទ្ធុប្បាទចេញហើយ មិនមានសោះឡើយ ។ ម្យ៉ាងទៀត ក្រៅពីអធិប្បញ្ញាដែលបានពោលមកហើយនោះ បញ្ញាដែលសម្បយុត្តដោយមគ្គនឹងផល ក៏ហៅថា អធិប្បញ្ញា ផងដែរ ។

សូមជ្រាបអំពីគោលនៃពុទ្ធសាសនា ដោយសេចក្ដីប្រមូលថា សីលជាជំហានទី ១ សមាធិជាជំហានទី ២ បញ្ញាជាជំហានទី ៣ នៃពុទ្ធសាសនា ។

គោលនៃពុទ្ធសាសនាចប់ដោយសង្ខេប ។

ព្រះពុទ្ធវង្ស កិម - តូរ

វត្តឧណ្ណាលោម

# សេចក្ដីផ្ដើម

អត្ថបទជាភាសាអង់គ្លេសខាងក្រោមនេះ គឺជាបាឋកថារបស់ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត - តាត អគ្គាធិការពុទ្ធិកសិក្សា បានថ្លែងក្នុងកាលនិមន្តទៅកាន់សហរដ្ឋអាមេរិក ក្នុងខែវិច្ឆិកា ឆ្នាំ ១៩៥៦ ។

ដោយយល់ឃើញថា អត្ថបទនេះមានប្រយោជន៍ច្រើនដល់ជនបរទេស, ទើបគណៈកម្មការនៃទស្សនាវដ្ដីពន្លឺពុទ្ធចក្រ នាំយកមកចុះផ្សាយទាំងស្រុងដូចតទៅនេះ ៖

## CAMBODIA : ITS PEOPLE, EDUCATION AND RELIGION

A Lecture

by

The Venerable Preah Pothivangsa Huot-Tath, Director of the Buddhist Lycee Preah Suramarit. Inspector of Buddhist Teaching in Cambodia.

---

1. At the outset I would like to express my great pleasure at the opportunity given to me to visit the United States of America on this occasion to speak to you. In the past such a thing would have been impossible. Now that it is possible and now that I am here, I would like to talk to you about my country, Cambodia.

2. Cambodia is one of the smallest countries in the world, little known to most people. For nearly one hundred years it was under a French protectorate and the general area in which it is located was known as French Indochina. This general area roughly embraces all the countries situated between India and China and includes Burma, Thailand, Cambodia, Laos and Vietnam. The term : French Indochina applies not to all of these countries but only to those occupied by the French, over which the French became the masters and exercised authority. These are three in number : Cambodia, Laos and Vietnam. During the past one hundred years the names of these countries were merged into one name : French Indochina, and for this reason Cambodia is not well known to the rest of the world.

3. I have said that Cambodia is a small country. Situated in South-east Asia it has an area of about 69,866 square miles and is bounded on the north by Laos, on the south by the Gulf of Thailand, on the east by Vietnam and on the west by Thailand. At the present time its population is about 5,000,000. When in recent years French rule was overthrown and Cambodia completely recovered its sovereignty, most of the world, including, first of all, the United States of America, accorded recongnition to Cambodia and have since sent their mission and representatives to work and carry out normal diplomatic relationships.

4. Although Cambodia is a small country and does not boast a large population, it has abundant resources, particularly agricultural. The fertile soil is very favorable to crops of

cereals and grows paddy-rice, corn. beans, peanuts, soya, sesame, cotton and tobacco. The principal staple of food is rice and with this the Cambodian people eat soups made of fish meat dishes and vegetables. Most of the people are farmers and earn their living by cultivating rice fields. They are plowed with the help of oxen or domesticated water-buffalos. In addition to this work the people spin and weave, making out of various materials scarves, mosquito netting, saris, phamuongs, hauls table-clothes and floor mats.

5. All such work is manual, without the aid of machines and though this is toilsome, the Cambodian people are happy with their work and their rice fields and love their country. The recent recovery of complete sovereignty is a step leading them towards the light of liberty and towards the progress which characterized the country centuries ago.

6. Now I would like to say a few words about Cambodia and Bouddhism.

The Cambodian people are adherents of the Buddhist religion. Long ago Buddhism extended its influence to Cambodia. It was accepted by the people who followed its light and considered it a source of strenght protecting them from fear and other disturbing emotions, enabling them to achieve what they wished for and hoped. The Buddhist religion taught Cambodians to overcome the vain superstitions which had existed prior to Buddhism. Since the religion's establishment in Cambodia, it has taken firm root, has never declined at any time and has exerted a strong influence on the country's arts and literature.

7. Buddhism was first taught in Cambodia in the third century of the Buddhist era by two missionary monks, Preah Sonathera and Preah Oudarathera, sent to preach Buddhism in Southeast Asia by King Thamasoka, ruler of ancient India, King Thamasoka was a warrior king. After having fought many battles in India he came to understand that war was nothing else than humanity destroying itself. He conceived clearly that only by prayer could humanity be brought to a state of security and he pledged himself to follow the teaching of Buddhism. During the period of the third Sermon in the third century he became the religion's leading advocate and sent missionaries for the first time to foreign countries to preach. He is, therefore, acknowledged as the first king to spread the light of Buddhism to the world.

8. Cambodia has become deeply Buddhist and its people have always followed the teaching of Buddhism. However, the religion reached the height of its glory in the eighteenth century of the Buddhist era during the reign of King Jayavarman VII, a faithful follower of Buddhism, who was responsible for the erection of many Buddhist temples, including that at Angkor. From the 20th to the 25th century of the Buddhist era Buddhism in Cambodia increased its scope and flory. At the present time one can see everywhere throughout the country large monasteries, temples and sacred buildings adorned with high horned roofs, full of yellow-robed priests and monks in such numbers that some tourists have commented that Cambodia is a country of monks.

## BUDDHISM AND THE PEOPLE

9. Cambodians, convinced of the truth of Buddhist doctrine, worship according to their religion and depend upon it to such a degree that even in circumstances of greatest misery they are willing to die for it. An example of the people's devotion to their Buddhist religion was seen in the ceremonies which took place in October 1955 in connection with the Burial of Buddha and of the relics of his disciples. Because the religion was established in the country so long ago, Buddhist teaching lies deep in the hearts of Cambodia from every walk of life. The

leaders of the country, from the King down to the lowest rank of officials, have understood the value of their religion, the state of peace of mind which it produces, andhence aecept it alone as their own. The Cambodian people, of their part rely on their religion, in its worship find solace and relief from pain and suffering. They believe in the principle of cause and effect; from good actions come good results, from bad actions, bad results. They educate their children accordingly and teach them to do good acts meriting future honor, persevering in their religions beliefs no matter what the future brings, mindful of the proverb: «Better to die than to give up prayer».

MONASTERIES

10. In every village there is usually a monastery, the residence of the Bhikhu and the Samanera (junior and senior monks). The entire kingdom with a population of five million people has 2,818 monasteries and 68,145 monks. Though the Cambodian people are not rich in property, they have a strong faith uniting their efforts, working like ants they raise funds at processions of «money-flowers» or simply by collections, the proceeds of which are used to support the monasteries, to build sacred houses and halls of wood, brick and tile. Indeed many monasteries have been built even of reinforced concrete.

11. Each monastery has at the very least three or four houses, halls and buildings for the Buddhist school and the school for children. There is also a temple for religious rites. It is built on an elevated spot, higher than the other buildings, adorned with a high horned roof that can be seen for many mfles indicating the location of the monastery from afar off. The expenses of building the monastery and of providing for the monks is taken care of by the villagers at all times. Even during a period of war or famine the Cambodian people will starve themselves in order to feed their monks.

12. This generosity of the Cambodian people is matched by their hospitality. Along the great roads and narrow pathways it has been the custom of the people to build rest halls, to plant shady trees, to place jars of water or even dig wells and cisterns for the comfort of the traveller. Such benevolent actions reveal their Buddhist sentiments, show that they distinguish between self-interest and the interests of others, take pity on men and animals, desire lasting peace for men and animals and a life devoid of such crimes as murder, theft, robbery, lies and deceptions. Buddhist teaching tells them: «Anyone who desires his own happiness, the happiness of his family and the prosperity of his country cannot achieve his desire by threatening others with force or with oppression. Peace cannot be established by arms. Peace can only exist as long as every human being takes pity on others and is friendly with others. As with individuals, so with nations, neverending reprisals can only be the result when persons distrust each other or when nations feel that other nations are against them. Vengeance springs from a burning heart». This Buddhist teaching lies deep in every Cambodian s heart and on it he bases his hope for the future.

THE MONKS

13. Monks are honored in Cambodia and reverence for them is integral to the Cambodian way of life. Though there are two religious orders of monks : The Mohanikay and the Thom mayut, these orders observe the same religious rule of life. The monks arise very early in the morning and go to the temple to pray, praising the beneficence of the Buddhist Trinity, meditating on Buddhist teachings and on the world. After their prayer they return to the monastery

to tidy up their living quarters or they clean the temple precincts and sacred monuments. They then set out begging in quest of food. After they have obtained and eaten their morning meal, they return to the monastery to attend classes and lectures. Before noon they eat their second meal of the day and in the afternoon they study privately. In the evening they return to the temple for prayers and meditation on the past and on the future of the Buddhist era. Some of the monks who find the monastery routine a distraction for them, seek the seclusion of the forest or some other remote place where they cloister themselves in meditation. Others teach children. Still others preach to the people educating them in Buddhist morality which forbids al bad actions, such as injuring anyone, and which exalts all forms of goodness.

14. The King of Cambodia is the first supporter of Buddhism. A Minister in the Cabinet is charged with the supervision of the monks and with the propagation of the Buddhist religion.

The supervision of the monks is along the following lines.

The Mohanikay Order is headed by one who has achieved the highest monastic rank, His Holiness Samdech Preah Moha Somethea Thippatey. His Holiness resides and has his offices in the Onalom monastery at Phnom-Penh and he is assisted by an Adviser with the title Samdach Oudom Proeksa. Also assisting him is a Council, of which he is the Head, composed of many monks of the greatest experience and knowledge.

15. In all of the Kingdom of Cambodia there are fourteen provinces. In each province here is one Abbot and several committees of monks who supervise all the monks in that province. Every province is subdivided into counties, each of which has a Superior and a committee composed of several other monks. In some counties where there are many monasteries the Superior is assisted by two other monks in the same capacity, though under him. There are also one or two laymen assigned to each monastery according to its importance by the Ministry of Cults. These cooperate with the Head of the Monastery and represent its lay parishioners in their relationships with the gouvernment authorities.

16. Of the two monastic orders in Cambodia the largest is the Mohanikay which this year has 2,715 monasteries snd 66,092 monks The smaller Order, the Thomayut, has 103 monasteries and 2,053 monks. It is headed by a monk of the highest rank, assisted by Advisers, all of whom have their residence and offices in the Botum Watey monastery at Phnom-Penh. This Order does not require the services of provincial Abbots or county Supervisors. Instead one Superior in each monatery acts under the direct supervision of the Head of the Order.

These two Orders, although organized along different lines, Keep in constant contact with each other and confer on programs necessary for the growth and welfare of Buddhism.

## EDUCATION OF THE CHILDREN

17. The Cambodian people educate their children in accordance with Buddhist doctrine. They send them to live and to be educated in the monasteries. Formerly Cambodian boys, including the sons of the King and of Ministers of State, lived for long periods in the monasteries where they went to school. Here they learned Cambodian culture, literature, mathematics, the arts, morality and the Buddhist way of life. It is to this type of education that the Cambodian people owe their temper of openness and frankness, their respect for the rights of others, From ancient times the core of Cambodian education has been parental instruction in the Buddhist religion and in the following of the Buddhist Trinity: Buddha, Thamma and Sangha. Children are taught the five and the eight Buddha rules and the ten commandments; they learn the virtues of respect and gratitude for their benefactors, including their mother and their father.

18. In Cambodia there are many national holidays : in April the New Year Festival, in May the anniversary of Buddha, in July the beginning of Vossa, the period of abstinence, in September, the commemoration of the Dead, in October the end of Vossa and the Festival of Gifts, in November the Water Festival, the moon Festival and the Festival of Independence. All these Vestivals, whether religious or popular, takê place in the monasteries, for here there is ample room for the people to enjoy themselves. Furthermore religious rites are an integral part of every celebration; this is especially true, of course, in the case of funerals and weddings during the ceremonies of which monks are invited by the people to pray and to preach Buddhist doctrine.

19. Cambodian people are not generally rich in this world's goods. They earn their living simply and are fond of doing good actions, they love tranquility, avoid domination and oppression. This is why some foreigners say that Cambodians are calm and withdrawn. This is quite true and it is due to their reverence for Buddha and their devotion to his teachings.

The teaching and principles of Buddhism do not conflict, however, with the pace of modern life or in any way impede modern progress. What it preaches to the people are basic truths accepted everywhere. An examination of these truths or principles reveal that Buddhism as a religion leads people along the rigth ways towards peace and progress and the best intereste of the human race. Let us examine some of these truths or principles so that we can pass judgement on them.

20. Buddha teaches :

1. Do not kill.
2. Do not steal, cheat or defraud.
3. Do not wrong in the heart and the passions.
4. Do not lie.
5. Do not calumniate or defame.
6. Do not scold or scorn.
7. Do not ridicule.
8. Do not take revenge or bear hatred.
9. Do not envy what belongs to others.
10. Do not guile.

21. All of us have the same wishes and desires for peace, rather than trouble; we prefer an honorable to a low position; we want goodness rather than badness; we long for property. Hence we fear death by violence, by murder, by war. We fear robbery, the rape of our wives or daughters; we fear calumny, scorn, hatred and vengeance. If this fear of evil restrains us from doing evil ourselves, then universal peace will be the result. Thi is the objective of Buddhism. This is the holy Buddhist doctrine that the Cambodian people adhere to. In it they place their hope for the welfare of the human race.

22 There are many more Buddhist rules of life and teachings which are based on a knowledge of those things which lead to destruction and those which lead to progress. I regret that I cannot discuss more of them now but our is limited. However, I would like to assure all of you that these rules of conduct and morality reach deep into the heart of every Cambodian. My people understand the utility and the value of their Buddhist religion, so long established among them and now still faithfully followed by them.

EDUCATION IN CAMBODIA

23. The Cambodian government under the leadership of the King, who is the sponsor of Buddhism, has organized its educational system into two divisions, the first being that of Public Examination and the second that of Buddhist Education. Public Education includes all the usual subjects; literature, mathematics, the sciences, etc., taught in Cambodia just as they are in the United States. Unfortunately our Public Education system, unlike that in the United States, does not yet reach the University level. Though we do not have a University the government is planning one and hopes to build soon. Since we have only recently achieved our Liberty and Independence, the organization of such matters, indeed the entire functioning of the government, requires time for all difficulties to be smoothed out.

24. Buddhist or Religious Education is organized along the following lines. In the large monasteries there are Buddhist Elementary schools where the monks teach Pali grammar, the Encyclopaedia of Buddhism, Buddhist discipline and rules and other general subjects as well. The course of study lasts for three years. Annually thousands of monks who have finished this elementary course pass their examinations and graduate. Those who wish to pursue their studies further, compete by examinations for entrance into secondary school where they will study for four more years. At the present time there is only one Buddhist secondary school, the Buddhist Lycée Preah Suramarit, located in Phnom-Penh and having an enrollment of 650 monks. In this school the subjects taught are Buddhism, Foreign Languages (French and English), Cambodian Literature, Mathematics, Science, Geography and History. Already thousands have graduated from this one school and in the future we expect to have similar Buddhist Lycées in the fourteen provinces, all teaching Buddhist doctrines as they are related to modern problems.

25. At the present time the government is constructing in Phnom-Penh a University which has been named Preah Sihanouk Reign Buddhist University. This Institution will specialize in graduate courses for qualifying monks who have finished their four years course of studies at the Buddhist Lycée Preah Suramarit. The full University course will take ten years. It is expected that by 1958 the University will begin its sessions and at the present time a curriculum of courses is being drawn up.

26. In addition to the arrangements just described, the government has also established schools of Buddhist moral teaching for junior and senior monks in every monastery of the country. Here they may study for one, two or three years, their work being carried out under the sponsorship of the King and under the supervision of the Heads of their respective Orders who are assisted by the Ministry of Cults.

27. Finally, the government has also established several other organizations for the development and spread of Bnddhism. A special Library contains encyclopedias, codices, rule-books and ordinances to assist in research. A Buddhist Academy has been instituted for the propagation of Buddhism abroad, to establish liaison and coordination with Buddhist programs in other Buddhist countries. The Academy publishes books and has set up a committee called the Tripitaka Committee which is composed of learned monks, well-versed in comparative religions, who are translating the Buddhist Laws from Pali and Sanskrit into Cambodian. This translation work can be classified a Great Sermon of Exegesis involving an appraisal of the correctness of the Buddhist Laws such as has been made from time to time in the past. For the first time in the history of Buddhism in Cambodia Buddhist scriptures are being translated into the Cambodian language and a Great Sermon of Exegesis, such as no country as ever yet seen, is being wrought.

28. Many private B ıddhist organizations flourish alongside the government ones I have already mentioned. These include the Buddhist world Association for the Far East in Cambodia, the Association of the Friends of Lycée Preah Suramarit, the Association for Medical Assistance to Cambodian monks. These organizations render valuable support to the Buddhist religion, assist in its propagation and in the coordination of Cambodian Buddhist activities in other parts of the Buddhist world.

29. Ladies and Gentlemen, counting from the time of Buddha's death and enlightenment until the present the Buddhist era has now reached its 2,500 anniversary. This anniversary is being celebrated all over the world by Buddhists who acknowledge the excellence of Buddha's teachings, who are manifesting their devotion to these teachings and who trust that through prayer and meditation the world will be made peaceful and secure. Without prayer there can be no peace in this world.

30. The Cambodian people are planning to celebrate this 2,500 anniversary in a solemn manner such as befits them as Buddhists. Each of them warmly hopes that his country will always be at peace, free from fear, free from disaster, enjoying the benefits of Buddhism. As the Buddhist era comes to its middle point, Cambodians, industrious and patient as they are, feel pleased with the present condition of their country. We have proof that our hope has achieved its object, for our country is making great intellectual and moral progress. As the knowledge of Buddhism spreads to other countries the world situation seems to change for the better, bringing about relief from tension, a lessening of world fears and a silencing of reciprocal threats that can only bring new wars and new destruction on the human race. Material progress alone in our atomic age cannot readily relieve international tension, for this progress also serves to create new weapons of war striking terror in our hearts. What is needed is that many nations sit down together, as they are doing, striving for a peace based on universal moral principles, working out practical formular for genuine friendship with each other, helping each other to rid the world of mesery, hatred and the spirit of revenge. All this most certainly is in accordance with Buddhist teaching.

31. Let me conclude by expressing my belief that the 2,500 anniversary of Buddhism can stand for all of us a symbol of the harmony which can exist between all peoples of the world. In prayer all the peoples of the world ask for peace and amity among nations. As we celebrate the closing of the first half of the Buddhist era and as we meditate on the teachings of Buddha, let us acknowledge these teachings as a powerful force for solving the problems of the world, for doing away with anger, spite, hatred and the spirit of revenge, for rooting out these causes of our insecurity and for our woe. May this anniversary be the turning point changing the old into new, raising the lowly to the heights and spreading peace all over the world.

32. In the world today there are five hundred millions Buddhists devoted to the teaching of Buddha, praying and meditating only for peace. Among these are five million Cambodians who feel that their country has been blessed in receiving the message of Buddha so long ago and in being faithful to that message through the centuries. For them the light of their Buddhist religion shines as a beacon to the world. If they remain faithful to their Buddhist tradition they feel that theirs is a source, a spring of never-failing water, cool and clear to quench the fires of world strife. It is their wish that through Buddhism peace and security progress and glory may be brought to the world. For this reason in every Cambodian monastery one can hear the prayer which echoes the teaching of Buddha to every monk in these words : «Endeavor to fulfill your duties without negligence.»

Recopy by Mr Huy-Ouch

# អដ្ឋសតតណ្ហាបញ្ហា

(សង្ខេប)

សួរថា — ក្នុងបដិច្ចសមុប្បាទ ពាក្យថា តណ្ហា បានដល់លោភៈ ពាក្យថា ឧបាទាន ក៏បានដល់លោភៈ តើលោភៈទាំងពីរនេះ មានសេចក្ដីផ្សេងគ្នាដូចម្ដេចខ្លះ ?

ឆ្លើយថា តណ្ហា បានដល់រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ជាលោភៈទាំងអស់, ចំណែកឧបាទាន បានដល់កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ជាលោភៈនិងទិដ្ឋិ. ប៉ុន្តែការសំខាន់នោះ តណ្ហាបានដល់លោភធម្មតា, ឧបាទាន បានដល់ការលោភមានកម្លាំងច្រើន ។

ក្នុងអភិធម្មត្ថវិភាវិនីបាលីថា ឯត្ថ ទុព្វលតណ្ហា តណ្ហា នាម ពលវតី ឧបាទានំ (ប្រែ) តណ្ហាដែលមានកម្លាំងតិច ឈ្មោះថា តណ្ហា តណ្ហាដែលមានកម្លាំងច្រើន ឈ្មោះថា ឧបាទាន ។

ន័យមួយទៀតបាលីថា បរិយេសនទុក្ខមូលំ តណ្ហា អារក្ខមូលំ ឧបាទានំ អយមេតេសំ វិសេសោ (ប្រែ) តណ្ហាមានទុក្ខក្នុងការស្វែងរកទ្រព្យសម្បត្តិជាមូល, ឧបាទានមានទុក្ខក្នុងការរក្សាទ្រព្យ-សម្បត្តិជាមូល, តណ្ហានិងឧបាទាន មានន័យផ្សេងគ្នា ដូចពោលមកនេះ ។ មានន័យខ្លះទៀតថា តណ្ហានិងឧបាទាន មានន័យជាមួយគ្នា ប៉ុន្តែផ្នែកដើមហៅថា តណ្ហា, ផ្នែកចុងហៅថា ឧបាទាន, ឬ មានកម្លាំងតិចហៅថា តណ្ហា មានកម្លាំងច្រើនហៅថា ឧបាទាន, ប៉ុន្តែឧបាទានរមែងកើតមានព្រោះតណ្ហា ដូចព្រះដីកាចារ្យលោកបានអធិប្បាយមកហើយ ។

ស. ការដែលលោករាប់តណ្ហា ១០៨ តើលោករាប់តាមគម្ពីរអ្វី? រាប់ដូចម្ដេចខ្លះ ?

ឆ. ការរាប់តណ្ហា ១០៨ មានក្នុងគម្ពីរច្រើនណាស់ ប៉ុន្តែក្នុងទីនេះ រាប់តាមន័យដីកាអភិធម្មត្ថវិភាវិនី និង អដ្ឋកថាវិភង្គ ក្នុងអភិធម្មត្ថវិភាវិនីបរិច្ឆេទទី ៨ បាលីថា :

កាមតណ្ហា ភវតណ្ហា វិភវតណ្ហាតិ តិវិធា តណ្ហា ឆឡារម្មណាទិវសេន បន អដ្ឋសតប្បភេទា ហោន្តិ (ប្រែ) តណ្ហាមាន ៣ យ៉ាងគឺ: កាមតណ្ហា ភវតណ្ហា វិភវតណ្ហា គុណដោយអំណាចនៃអារម្មណ៍៦ ជាដើម បានជាតណ្ហា ១០៨ ប្រភេទ ។

ក្នុងអដ្ឋកថាវិភង្គបាលីថា ឥតិ អតីតា ឆត្តឹស អនាគតា ឆត្តឹស បច្ចុប្បន្នា ឆត្តឹស អដ្ឋសតំ

ហានិ (ប្រែ) តណ្ហា អតីត ៣៦ តណ្ហាអនាគត ៣៦ តណ្ហាបច្ចុប្បន្ន ៣៦ រួមជាតណ្ហា ១០៨ ។

អធិប្បាយថា តណ្ហា ៣ គឺ: កាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១, យកតណ្ហា ៦ គឺ រូបតណ្ហា ១, សទ្ទតណ្ហា ១, គន្ធតណ្ហា ១, រសតណ្ហា ១, ផោដ្ឋព្វតណ្ហា ១, ធម្មតណ្ហា ១, ទាំង៦នេះទៅគុណជាមួយតណ្ហា ៣ គឺ: កាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១ បានជា ១៨ហៅថា តណ្ហាខាងក្នុង ។ យកតណ្ហា ៦ទៀតគឺ: រូបតណ្ហា ១, សទ្ទតណ្ហា ១, គន្ធតណ្ហា ១, រសតណ្ហា ១, ផោដ្ឋព្វតណ្ហា ១, ធម្មតណ្ហា ១, ទាំង៦នេះទៅគុណជាមួយតណ្ហា ៣ គឺ កាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១, រួមជា ១៨ ហៅថា តណ្ហាខាងក្រៅ រួមជា ៣៦ ។ យកតណ្ហាជាអតីត ៣៦, យកតណ្ហាជាអនាគត ៣៦, យកតណ្ហាជាបច្ចុប្បន្ន ៣៦ រួមជា ១០៨ (៣៦×៣=១០៨) ។

ស តណ្ហាទាំង៣នោះ តើបានដល់អ្វី? ហេតុដូចម្ដេចទើបមានឈ្មោះថាតណ្ហា, សូមឆ្លើយព្រមទាំងអាងគោលឲ្យាក់ឲ្យបានដែលល្មមគួរជឿបានមកមើល ?

ឆ. រឿងតណ្ហានេះ មានអស់លោកបណ្ឌិតអ្នកប្រាជ្ញ ពោលច្រើនយ៉ាងច្រើនន័យណាស់ តែការពោលដែលត្រឹមត្រូវតាមការណ៍ពិតនោះ ស្ទើរតែមិនមានសោះក៏ថាបាន ប៉ុន្តែក្នុងទីនេះ នឹងលើកយកតាមពាក្យ: ដែលមានគោលអាងព្រមទាំងវិគ្គហស័ព្ទដូចតទៅ ៖

ពាក្យថា កាមតណ្ហា មានវិគ្គហស័ព្ទថា កាមេតីតិ កាមោ, កាមោ ច សោ តណ្ហា ចាតិ កាមតណ្ហា (ប្រែ) សេចក្ដីត្រូវការអារម្មណ៍ទាំង ៦ ហៅថាកាម. វិគ្គហទី២ សេចក្ដីថា ការត្រូវការដែលឈ្មោះថា កាមនេះហើយ ឈ្មោះថាតណ្ហា ហៅថា កាមតណ្ហា បានដល់សេចក្ដីត្រេកអរ ត្រូវការអារម្មណ៍ ទាំង ៦នោះឯង ។

ពាក្យថា ភវតណ្ហា វិគ្គហថា ភវតីតិ ភវោ, ភវោ ច សោ តណ្ហា ចាតិ ភវតណ្ហា (ប្រែ) សេចក្ដីថា រមែងកើតក្នុងភពផ្សេង ៗ ដូច្នោះ ហៅថា ភវតណ្ហា បានដល់សេចក្ដីត្រូវការភពដែលមិនមានការបែកធ្លាយ គឺ:សស្សតទិដ្ឋិនោះឯង, តណ្ហានេះកើតមកអំពីកាមតណ្ហា ឬថាជាសាខារបស់កាមតណ្ហាក៏ថាបាន ។

ពាក្យថា វិភវតណ្ហា វិគ្គហថា ន ភវតីតិ វិភវោ, វិភវោ ច សោ តណ្ហា ចាតិ វិភវតណ្ហា (ប្រែ) សេចក្ដីថា រមែងមិនកើត ដូច្នោះហៅថា វិភវ: វិភវ:នេះហើយឈ្មោះថាតណ្ហា ហៅថា វិភវតណ្ហា បានដល់សេចក្ដីត្រូវការភពជាតិ ដោយប្រាសចាកហេតុផល ឬ តាមកាសាធម៌ គឺគឺ: ឧច្ឆេទទិដ្ឋិនោះឯង

តណ្ហានេះ ផ្តើមមកដោយឧច្ឆេទទិដ្ឋិ ដូចជាភវតណ្ហាដែលបានអធិប្បាយមកហើយ ។

តណ្ហាទាំង ៣ នេះ ពោលដោយសង្ខេប បានដល់សេចក្តីត្រូវការអារម្មណ៍ទាំង ៦

សេចក្តីត្រូវការអារម្មណ៍ទាំង ៦ នេះ កាលបើប្រកបដោយសស្សតទិដ្ឋិ ហៅថា ភវតណ្ហា កាលបើប្រកបដោយឧច្ឆេទទិដ្ឋិ ហៅថា វិភវតណ្ហា ព្រោះហេតុនោះ កាលបើរាប់តណ្ហា ១០៨ ត្រូវយកតណ្ហា ៣ គឺៈ កាមតណ្ហា ១, ភវតណ្ហា ១, វិភវតណ្ហា ១ ។ យកតណ្ហា ៦ គឺៈ រូបតណ្ហា ១, សទ្ទតណ្ហា ១, គន្ធណ្ហា ១, រសតណ្ហា ១, ផោដ្ឋព្វតណ្ហា ១, ធម្មតណ្ហា ១, យក ៣ គុណ ៦ បានជា ១៨ ខាងក្នុង, ១៨ ខាងក្រៅ រួម ៣៦; អតីត ៣៦, អនាគត ៣៦, បច្ចុប្បន្ន ៣៦, រួមជា ១០៨ ។

ក្នុងបដិច្ចសមុប្បាទ វិភង្គអដ្ឋកថា និងវិសុទ្ធិមគ្គតតិយភាគ បត្ត: ៣៩៩ ត្រង់វេទនាបច្ចយាតណ្ហាបទ ដូចមានបទបាលីថា :

រូបតណ្ហាទិភេទេន ឆ តណ្ហា ឯត្ថ ទីបិតា

ឯកេកា តិវិធា តត្ថ បវត្តាការតោ មតា ។

ឯត្ថ ហិ បទេ សេដ្ឋិបុត្តោ ព្រាហ្មណបុត្តោតិ បិតិតោ នាមវសេន បុត្តោវិយ រូបតណ្ហា សទ្ទគន្ធរសផោដ្ឋព្វធម្មតណ្ហាតិ អារម្មណតោ នាមវសេន វិភត្តា ឆ តណ្ហា ទីបិតា ។ តាសុ បន តណ្ហាសុ ឯកេកា តណ្ហា បវត្តិអាការតោ កាមតណ្ហា ភវតណ្ហា វិភវតណ្ហាតិ ឯវ តិវិធា មតា ។

រូបតណ្ហាយេវ ហិ យទា ចក្ខុស្សាបាថមាគតំ រូបារម្មណំ កាមស្សាទវសេន អស្សាទយមានា បវត្តតិ តទា កាមតណ្ហា នាម ហោតិ, យទា តទេវារម្មណំ ធុវំ សស្សតន្តិ បវត្តាយ សស្សតទិដ្ឋិយា សទ្ធឹ បវត្តតិ តទា ភវតណ្ហា នាម ហោតិ, សស្សតទិដ្ឋិសហគតោ ហិ រាគោ ភវតណ្ហាតិ វុច្ចតិ, យទា បន តទេវារម្មណំ ឧច្ឆិជ្ជតិ វិនស្សតីតិ បវត្តាយ ឧច្ឆេទទិដ្ឋិយា សទ្ធឹ បវត្តតិ តទា វិភវតណ្ហា នាម ហោតិ, ឧច្ឆេទទិដ្ឋិសហគតោ ហិ រាគោ វិភវតណ្ហាតិ វុច្ចតិ ។

ឯស នយោ សទ្ទតណ្ហាទីសុបីតិ ។ ឯតា អដ្ឋារស តណ្ហា ហោន្តិ ។ តា អជ្ឈត្តរូបាទីសុ អដ្ឋារស ពហិទ្ធា អដ្ឋារសាតិ ឆត្តឹស ។ ឥតិ អតីតា ឆត្តឹស អនាគតា ឆត្តឹស បច្ចុប្បន្នា ឆត្តឹសាតិ អដ្ឋសតតណ្ហា ហោន្តិ ។

ប្រែ

តណ្ហាទាំង ៦ លោកពោលទុកក្នុងទីនេះ តាមប្រភេទនៃតណ្ហា មានរូបតណ្ហាជាដើម; (បណ្តាតណ្ហា

ទាំងឡាយនោះ) តណ្ហាមួយ ៗ លោកពោលដោយអាការ ៣ យ៉ាង តាមអាការដែលតណ្ហាប្រព្រឹត្តទៅ ៗ

សេចក្ដីក្នុងបទនេះ តណ្ហាទាំង ៦ ដែលលោកពោលទុកក្នុងវិភង្គ ដោយអំណាចនៃឈ្មោះតាមអារម្មណ៍ថា រូបតណ្ហា, សទ្ទតណ្ហា, គន្ធតណ្ហា, រសតណ្ហា, ផោដ្ឋព្វតណ្ហា, ធម្មតណ្ហា ដូចជាកូនដែលគេហៅដោយអំណាចនៃឈ្មោះខាងបិតាថា កូននៃសេដ្ឋី កូននៃព្រាហ្មណ៍ ៗ មួយទៀត បណ្ដាតណ្ហាទាំងឡាយនោះ តណ្ហាមួយ ៗ លោកពោលដោយអាការ ៣ ៗ យ៉ាងនេះថា កាមតណ្ហា; ភវតណ្ហា; វិភវតណ្ហា តាមអាការដែលប្រព្រឹត្តទៅ ៗ

សេចក្ដីពិតថា រូបតណ្ហា កាលត្រេកអរនូវរូបារម្មណ៍ ដែលមកកាន់វង្វង់នៃចក្ខុប្បសាទ ប្រព្រឹត្តទៅដោយអំណាចនៃសេចក្ដីត្រេកអរក្នុងកាម កាលណា កាលនោះឈ្មោះថា កាមតណ្ហា, តណ្ហាប្រព្រឹត្តទៅមួយអន្លើ ដោយសស្សតទិដ្ឋិ ប្រព្រឹត្តទៅដោយសេចក្ដីយល់ ថា អារម្មណ៍នោះ ឋិតថេរ ទៀងទាត់ កាលណា កាលនោះ ឈ្មោះថា ភវតណ្ហា មួយទៀត រាគដែលប្រកបដោយសស្សតទិដ្ឋិ លោកពោលថា ភវតណ្ហាដែរ, តណ្ហាប្រព្រឹត្តទៅមួយអន្លើដោយ ឧច្ឆេទទិដ្ឋិ ប្រព្រឹត្តទៅដោយសេចក្ដីយល់ថា អារម្មណ៍នោះ ដាច់សូន្យទៅ វិនាសទៅ កាលណា, កាលនោះឈ្មោះថា វិភវតណ្ហា; មួយទៀត រាគៈ ដែលប្រកបដោយឧច្ឆេទទិដ្ឋិ លោកហៅថា វិភវតណ្ហាដែរ ៗ

បណ្ឌិតគប្បីយល់នូវន័យនេះក្នុងតណ្ហាទាំងឡាយ មានសទ្ទតណ្ហា ជាដើមទៅ ៗ តណ្ហាទាំងឡាយនោះមាន ១៨ ៗ តណ្ហាទាំងឡាយនោះមាន ៣៦ គឺ ១៨ ខាងក្នុងមានរូបារម្មណ៍ជាដើម, ១៨ ខាងក្រៅ (មានរូបខាងក្រៅ) ៗ តណ្ហាទាំងឡាយ ១០៨ គឺ អតីត ៣៦ អនាគត ៣៦, បច្ចុប្បន្ន ៣៦ ៗ

ព្រះទេពមុនី ទ្រាង - ប៊ុល

# ការសំដែងធម៌

សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។ល។ បរិយោសានកល្យាណំ(១) ។

ព្រះមានព្រះភាគ កាលទ្រង់សំដែងធម៌ តិចក្តី ច្រើនក្តី ដោយទ្រង់អាស្រ័យនូវសេចក្តីករុណាភាពចំពោះសត្វទាំងឡាយ មានពីរោះលំអ ៣ បែប គឺ:

១–បែបពីរោះខាងដើម បានដល់សីលដែលជាប្រយោជន៍ចំពោះខ្លួន (អាទិកល្យាណំ) ។

២–បែបពីរោះត្រង់កណ្តាល បានដល់ សមថ-វិបស្សនា-មគ្គ និង ផល (មជ្ឈេកល្យាណំ) ។

៣–បែបពីរោះខាងចុងចប់ បានដល់ ព្រះនិព្វាន . . . (បរិយោសានកល្យាណំ) ។

សាសនធម៌ទាំងអស់ ទ្រង់ប្រកាសដ៏បរិបូណ៌ដោយអត្ថនិងព្យញ្ជនៈ ដោយន័យមានបែបបទផ្សេងៗ មានពីរោះដោយបឋមបាទ ទុតិយបាទ តតិយបាទ និងអនុសន្ធិ១ ជាដើម ។ ព្រោះទ្រង់មានប្រាថ្នាចង់ឲ្យអ្នកស្តាប់បានទទួលលទ្ធផលសម្រេចប្រយោជន៍គឺ សទ្ធាបដិលាភ សូម្បីអ្នកស្តាប់មានសន្តានចិត្តជាមនុស្សរបឹងរឹងរូស កាចឃោរឃៅប្រកបដោយអស្មិមានះប្រកាន់ខ្លួនថា: «អញចាស់អាយុច្រើន មានយសសក្តិចេះដឹងជាងគេ» ទ្រង់ក៏ប្រកាសសាសនធម៌បំបែរបញ្ចោរមនុស្សនោះៗ ឲ្យត្រឡប់មកកាន់សេចក្តីជ្រះថ្លាជឿព្រះប្រាជ្ញាញាណរបស់ព្រះអង្គវិញ ។

មានសេចក្តីដំណាលថា: កាលព្រះអង្គគង់នៅក្បែរដើមស្តៅរបស់យក្សឈ្មោះ នឡេរុ ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃ៥០០អង្គ ។ មានព្រាហ្មណ៍ម្នាក់ចាស់ឈ្មោះវេរញ្ជៈ បានចូលទៅគាល់ព្រះសម្ពុទ្ធ ហៅព្រះអង្គថា: ព្រះគោតមដ៏ចំរើន ខ្ញុំបានឮគេនិយាយបរិយាយថា: «ព្រះសមណគោតម មិនថ្វាយបង្គំចាស់ព្រឹទ្ធាចារ្យ មានសក់ស្កូវ ធ្មេញបាក់ អវយវៈទ្រុឌទ្រោម មានអាយុ២-៣ ពង្សស្តេចមកហើយ ប្រកបដោយគុណសីលាចារៈ ឬអ្នកមានទ្រព្យសម្បត្តិ ក៏លោកមិនថ្វាយបង្គំ មិនក្រោកទទួល មិនអញ្ជើញគេដោយអាសនៈ ដូចនឹងមែនឬ?», កិរិយាបែបនេះ មិនត្រឹមត្រូវទេ! មិនទំនងដល់សមណគោតមឡើយ ។

ព្រះមានព្រះភាគទ្រង់មានព្រះទ័យប្រកបដោយមហាករុណាដ៏ត្រជាក់សំដែងនូវការណ៍គួរចំពោះព្រាហ្មណ៍ចាស់ថា: ម្នាល ព្រាហ្មណ៍ តថាគតមិនឃើញមានបុគ្គលណា ដែលគួរថ្វាយបង្គំ គួរក្រោកទទួល គួរអញ្ជើញដោយអាសនៈ តាំងពីលោកនេះរហូតដល់ទៅទេវលោក, នែព្រាហ្មណ៍ អ្នកកុំប្រាថ្នាការប៉ុនប៉ងចង់បានសេចក្តីគោរពពីតថាគត បើតថាគតថ្វាយបង្គំអ្នកណា អ្នកនោះនឹងដាច់ក្បាលធ្លាក់ចោលទៅលើផែនដី ដូចផ្លែត្នោត

---

១ ចាកគម្ពីរបឋមសមន្ត . . . ត្រង់វេរញ្ជកណ្ឌវណ្ណនា (បំប្រួញសេចក្តី) ។

ទុំរបូតផ្ទុះតាកទងដូច្នោះដែរ ។ ព្រោះតថាគតជាអគ្គបុគ្គល ជាធំ ប្រសើរជាងសត្វលោក ។

ព្រាហ្មណ៍មិនជឿ ទើបពោលប្រទេចថា: ព្រះគោតម ជា អរសរូបោ មានរូបតែឥតរសជាតិ ព្រោះគ្មានប្រវេណីនិយម, រសជាតិនេះ ព្រាហ្មណ៍សំដៅយកសាមគ្គីរស គឺការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងការគោរពកោតក្រែង ។

ព្រះមានព្រះភាគ ទ្រង់ចៀសវាងការឈ្លោះប្រកែក ទើបត្រាស់ថា: ការបរិយាយនោះត្រូវហើយ រាប់បានថាមិនប្រែប្រួលខុស ព្រោះរសជាតិ គឺអារម្មណ៍ដែលពួកបុថុជ្ជនជាប់ចិត្តសន្មតថាប្រសើរ បានដល់ រូប សំឡេង ក្លិន រស សម្ផស្ស ដែលតថាគតលះបង់ចោលដាច់ស្រឡះហើយ ។ ឯមូលរបស់តណ្ហានិងអវិជ្ជា ក៏តថាគតកាត់ផ្តាច់ដោយកាំបិត គឺអរិយមគ្គ ធ្វើឲ្យមានឫសផ្ការឡើងលើ ដូចដើមត្នោតដែលគេគាស់រំលើងឫស ធ្វើឲ្យឫសផ្ការឡើងលើមិនឲ្យដុះលូតលាស់ឡើងវិញដូច្នោះដែរ ។

ព្រាហ្មណ៍ថា: និព្ភោគោ បពិត្រព្រះគោតម លោកជាអ្នកមិនមានសម្បត្តិគ្រឿងបរិភោគ គឺព្រាហ្មណ៍ សំដៅយកសាមគ្គីរសជាសម្បត្តិល្អរបស់មនុស្សលោក ។

ព្រះមានព្រះភាគត្រាស់ថា ការបរិយាយនេះត្រឹមត្រូវហើយ ព្រោះសម្បត្តិគ្រឿងបរិភោគ គឺ ឆន្ទរាគ របស់មនុស្សមានរសគឺរូបជាដើម តថាគតលះបង់ចោលដាច់ស្រឡះអស់រលីងហើយ ។

ព្រះសមណគោតម ជា អកិរិយវាទ ពោលបដិសេធមិនធ្វើ គឺការមិនធ្វើបុណ្យបាបឥតអំពើ មិនមែន ហៅថាធ្វើទេ. . . . ។

ព្រះមានព្រះភាគត្រាស់ថា អើ! ការបរិយាយនោះត្រូវហើយ ព្រោះតថាគតពោលបដិសេធនូវការមិនធ្វើ ទុច្ចរិតដោយ កាយ វាចា ចិត្ត ដែលតថាគតលះបង់ចោលអស់ហើយ ។

ព្រះសមណគោតមជា ឧច្ឆេទវាទ ជាអ្នកប្រកាសនូវការដករំលើងប្រវេណីរបស់លោក ដែលអាស្រ័យ និងលោកដាច់សូន្យហើយ គឺព្រាហ្មណ៍សំដៅនូវការដករំលើងទំនៀមទម្លាប់ចរិតល្អរបស់មនុស្សលោក ។

ព្រះមានព្រះភាគត្រាស់ថា: ការបរិយាយនេះត្រូវហើយព្រាហ្មណ៍! ព្រោះតថាគតបាន ដករំលើងចោលនូវ កាមគុណ ៥ ព្រមទាំងលោភមូល ៨ ដែលជាអកុសលចិត្តដោយអនាគាមិមគ្គ, កាត់ផ្តាច់មោហៈ ដោយ អរហត្តមគ្គ និង អកុសលលាមកដោយមគ្គ ៤ ។

ព្រះសមណគោតមជា ជេគុច្ឆី អ្នកខ្ពើមរអើម នូវការថ្វាយបង្គំ ការគោរព គឺព្រាហ្មណ៍សំដៅដល់សាមគ្គី

រសរបស់អ្នកល្អក្នុងលោក ។

ព្រះមានព្រះភាគត្រាស់ថា: ការបរិយាយនេះត្រូវហើយ ព្រោះតថាគតខ្ពើមរអើមនូវសេចក្តីប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ដូចបុរសដែលស្អិតស្អាងកាយស្អាត តែងខ្ពើមរអើមខ្លាចនូវដុំលាមកមកប្រឡាក់ខ្លួនគេដូច្នោះដែរ ។

ព្រះសមណគោតមជា វេនយិកៈ អ្នកនាំឲ្យវិនាស គឺញុំាងសេចក្តីគោរពកោតក្រែងឲ្យវិនាស គួរតែសង្កត់សង្កិននូវកិរិយានោះ គឺព្រាហ្មណ៍សំដៅសេចក្តីថា: អ្នកធ្វើសាមគ្គីរសដែលជាប្រវេណីរបស់លោកឲ្យវិនាស ។

ព្រះមានព្រះភាគត្រាស់ថា: ការបរិយាយនោះត្រូវហើយ ព្រោះតថាគតបានញុំាងកិលេសគឺ រាគៈ ទោសៈ មោហៈ ឲ្យវិនាស ទាំងបាននាំចេញនូវបាបគ្រប់ជំពូកឲ្យវិនាសដែរ ។

ព្រះសមណគោតម ជា តបស្សី អ្នកដុតកំដៅជនចាស់ ៗ ឲ្យលំបាកលំបិន, គឺព្រាហ្មណ៍សំដៅដល់ការមិនធ្វើសេចក្តីគោរពទទួលជនចាស់ទុំធំ ៗ គឺដុតបំផ្លាញជនចាស់ ៗ ឲ្យក្តៅក្រហាយឲ្យទោមនស្សត្អូញចិត្ត ។

ព្រះមានព្រះភាគត្រាស់ថា: ការបរិយាយនេះត្រូវហើយ ព្រោះធម៌ជាអកុសលគួរដល់កិរិយាក្តៅក្រហាយដែលសត្វប្រព្រឹត្តធ្វើអាក្រក់ដោយ កាយ វាចា ចិត្ត តថាគតបានដុតបំផ្លាញចោលអស់ហើយ ។

ព្រះគោតមជា អបគព្ភោ អ្នកប្រាសចាកគភ៌ មិនគួរកើតក្នុងទេវលោកជាមនុស្សកើតក្នុងគភ៌ដ៏ថោកទាប គឺព្រាហ្មណ៍សំដៅដល់ការមិនកើត ព្រោះសំគាល់ព្រះអង្គថា: មិនធ្វើអភិវាទនកម្មថ្វាយបង្គំចាស់ទុំធំ ៗ ជាដើម ។

ព្រះមានព្រះភាគត្រាស់ថា: ការបរិយាយនេះត្រូវហើយ ព្រោះការដេកទៅក្នុងគភ៌ ការកើតក្នុងភពតទៅ តថាគតបានលះដាច់ស្រឡះហើយ (លែងកើតទៀតហើយ) ។

ព្រះសម្ពុទ្ធ ជាធម្មរាជទ្រង់ផ្សាយករុណាធម៌ចំពោះព្រាហ្មណ៍ ដោយដឹងគំនិតព្រះទ័យថា: « ព្រាហ្មណ៍នេះគ្រាន់តែដឹងខ្លួនថា: អញចាស់ ដោយយកហេតុ សក់ស្កូវ ធ្មេញបាក់ ស្បែកស្វិតជ្រួញជ្រីវមកអាងថាចាស់ នៅមិនទាន់ដឹងខ្លួនថា ជាតិ ជរា ព្យាធិ មរណៈ ដេញតាមទាន់ជាន់កែងជិះជាន់គ្រប់សង្កត់ជាប់លបបំផ្លាញឲ្យស្លាប់មិនដឹងថាខ្លួនស្លាប់ថ្ងៃនេះឬថ្ងៃស្អែក ដូចកូនក្មេងតូចដែលដេកផ្ងារក្នុងអង្រឹង ៗ ទើបព្រះអង្គត្រាស់ថា :

ម្នាលព្រាហ្មណ៍ មេមាន់មានស៊ុត ៨ ឬស៊ុត ១០ ឬ ស៊ុត ១២ មេមាន់នោះបានត្រដាងស្លាបក្រាបគ្របអប់ចំហាយឲ្យស៊ុតល្អមិនឲ្យស្អុយ កូនមាន់ណាដែលបានចោះសំបកស៊ុតបែកចេញមកខាងក្រៅបានមុនគេ កូនមាន់នោះគួរហៅដូចម្តេច! ថាបងឬប្អូនគេ! គួរហៅថាបងគេ ព្រោះញាស់ចេញមកបានមុនគេ យ៉ាងណា

តថាគត ក៏យ៉ាងនោះដែរ, ដូចពួកសត្វដែលនៅក្នុងសំបកស៊ុតមាន់គឺអវិជ្ជារុំស្រោបហ៊ុំទុក ។

ឯតថាគតបានចោះទំលាយសំបកស៊ុតមាន់គឺអវិជ្ជា បានឃើញពន្លឺ គឺបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណតែម្នាក់ឯងមុនគេ តថាគតទើបបានជាបងរបស់សត្វលោកមុនគេ ។

ព្រាហ្មណ៍បានស្តាប់ធម៌រឿងចោះទំលាយសំបកស៊ុតមាន់គឺអវិជ្ជាដរាបដល់ចប់ កើតមានសេចក្តីជ្រះថ្លាសរសើរថា: «ការសំដែងធម៌នេះពីរោះណាស់ ៗ ដូចជាគេបើករបស់ដែលគ្របទុកឲ្យឃើញ ឬ ដូចជាគេកាន់ប្រទីបបំភ្លឺផ្លូវដែងងឹតឲ្យឃើញអ្វី ៗ គ្រប់យ៉ាង ។

ព្រាហ្មណ៍ក៏បានប្រកាសខ្លួនជាឧបាសក សូមដល់ព្រះរតនត្រ័យជាទីពឹងដរាបដល់អស់ជីវិត ។

នេះហើយ ព្រះពុទ្ធជាម្ចាស់ មានព្រះបញ្ញាញាណដ៏ឈ្លៀវឈ្លាសសំដែងធម៌ប្រោសវេរញ្ជព្រាហ្មណ៍ប្រកបដោយព្រះទ័យមេត្តា ករុណា ចាត់ជាព្រះពុទ្ធដីកាមានសារៈប្រយោជន៍ប្រាកដបានពេញទី ចំពោះព្រាហ្មណ៍ដែលកំពុងតែពោលដោយសេចក្តីក្រោធតទល់នឹងព្រះអង្គ ។

ចប់ដោយសង្ខេប ។

ការសំដែងធម៌

របស់

ព្រះឃោសធម្ម

កៅ - ស៊ុម

# បញ្ហា ៣ ខ

លោក ទ្រឿង-ធរលក្ខណ៍ គ្រូបង្រៀន ឃុំពុកឫស្សី ស្រុកខ្សាច់កណ្ដាល ខេត្ត កណ្ដាល បានអានទស្សនាវដ្ដី ពន្លឺពុទ្ធចក្រ ដែលផ្សាយចេញលើកទី ១ មានសេចក្ដីឆ្ងល់ខ្លះ ទើបចងជាសំនួរហើយផ្ញើមកយើងឲ្យដោះស្រាយ យើងបានលើកយកសំនួរនោះនឹងសេចក្ដីឆ្លើយរបស់យើង មកចុះក្នុងទស្សនាវដ្ដី ពន្លឺពុទ្ធចក្រ ដូចតទៅនេះ ៖

លោក ទ្រឿង-ធរលក្ខណ៍ បានលើកយកបញ្ហា ៣ ខ

មកពោលសួរថា

១– អំពើអាក្រក់ដែលសត្វធ្វើទៅហើយ តែងឲ្យផលអាក្រក់ក្នុងលោកនេះនឹងលោកខាងមុខ ។

២– អំពើអាក្រក់ដែលសត្វធ្វើទៅហើយ គ្រាន់តែញុំាងសត្វនោះឲ្យរងទុក្ខទោសតែក្នុងលោកនេះ លុះដល់លោកខាងមុខ សត្វនោះគ្មានរងទុក្ខទោសឡើយ ។

៣– អំពើអាក្រក់ដែលសត្វធ្វើទៅហើយ នឹងញុំាងសត្វនោះឲ្យរងទុក្ខវេទនាក្នុងលោកខាងមុខ ចំណែកខាងក្នុងលោកនេះ បែរជាគ្មានទោសអ្វីឡើយ ។

អំពើទី ១ ខាងលើនោះ ខ្ញុំបាទយល់បានថាមានពិតប្រាកដហើយ នៅសល់តែអំពើទី ២ នឹងទី ៣ តើមានឬទេ ? បើមានគឺជាអំពើដូចម្ដេចខ្លះ ? ញុំាងសត្វឲ្យទទួលទុក្ខទោសបែបណា ?

សេចក្ដីឆ្លើយតបនឹងបញ្ហារបស់លោក ទ្រឿង-ធរលក្ខណ៍ ដូចតទៅនេះ ៖

បញ្ហាទី ១ យើងមិនបាច់ដោះស្រាយទេ ព្រោះលោកជាស្ដាប់បានយល់ចូលចិត្តអស់ហើយ ។

បញ្ហាទី ២ « អំពើអាក្រក់ដែលសត្វធ្វើទៅហើយ គ្រាន់តែញុំាងសត្វនោះឲ្យរងទុក្ខទោសតែក្នុងលោកនេះ ឯក្នុងលោកខាងមុខគ្មានរងទុក្ខទោសទេ » ត្រង់នេះសំដៅយកអំពើអាក្រក់ណាមួយ ដែលប្រព្រឹត្តល្មើសកន្លងបទបញ្ញត្តិខ្លះសម្រាប់ប្រទេស ដែលរាជការបានបញ្ញត្តហាមហើយ ដូចជាលេងកន្ទុយលេខឆ្នោត ឬល្បែងស៊ីសងឯទៀតជាដើម អ្នកណាទៅប្រព្រឹត្តកន្លងបទបញ្ញត្តិនោះ ឬក៏ប្រព្រឹត្តអំពើល្បែង កុន ពេក្ខន ឬ ល្បែងអបាយមុខណាមួយ អ្នកនោះឯងត្រូវទទួលទុក្ខទោសដោយរាជការផ្ដន្ទាទោស ឬដោយការហិនហោចទ្រព្យសម្បត្តិធ្លាក់ខ្លួនទៅជាអ្នកក្រីក្រដុនដាប ទោសទាំងនេះមានតែក្នុងលោកនេះ ឯក្នុងលោកខាងមុខពុំមានឡើយ ។

បញ្ហាទី ៣ « អំពើអាក្រក់ដែលសត្វធ្វើទៅហើយ នឹងញុំាងសត្វនោះឲ្យរងទុក្ខវេទនាក្នុងលោកខាងមុខ

ចំណែកខាងក្នុងលោកនេះ គ្មានទោសអ្វីឡើយ » ត្រង់នេះគួរជ្រាបថា អំពើអាក្រក់ទាំងឡាយណាមួយ មានការបៀតបៀន សម្លាប់សត្វ បំបាត់ជីវិតគេ ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិគេជាដើម អំពើនោះៗ ជួនកាលឲ្យទោសក្នុងលោកនេះផងក្នុងខាងមុខផង ជួនកាលក្នុងលោកនេះមិនឲ្យទោសទេ ដល់ទៅក្នុងលោកខាងមុខ ទើបឲ្យទោស ពុំនោះសោតដូចការសម្លាប់ សង្កើច, ចៃ, មូស ជាសត្វល្អិតតូចតាច ក្នុងលោកនេះគ្មាននរណាធ្វើទុក្ខទោសដល់ខ្លួនអ្នកសម្លាប់មែន ប៉ុន្តែទៅក្នុងលោកខាងមុខត្រូវតែទទួលទុក្ខទោសក្នុងជាតិកំណើតណាមួយពុំខាន ។ ចំណែកខាងអំពើអាក្រក់ខ្លះក្នុងលោកនេះ ដែលមិនឲ្យទោសនោះ ដោយហេតុថាបុគ្គលអ្នកធ្វើនោះឯង មានបរយោគ-សម្បត្តិគ្រប់គ្រាន់ គឺជាអ្នកប៉ិនប្រសប់បេះលៃលកទុកដាក់ខ្លួនកែកុនទាយសាយ តាមកាលៈទេសៈ ដោយឧបាយថា ពេលនេះគួរចូលទៅរក, ពេលនេះគួរថយគេចចេញដូច្នេះជាដើម អ្នកនោះជួនកាលក៏ដោះខ្លួនចៀសផុតពីទុក្ខទោសក្នុងលោកនេះបាន ប៉ុន្តែទៅក្នុងលោកខាងមុខពិតជាពុំរួចផុតឡើយ ។ ន័យក្នុងបញ្ហាទី ៣ ដែលបានឆ្លើយតបនេះ បើអ្នកពុំទាន់ស្តាប់បានទេ ចូរអ្នកចោលភ្នែកក្រឡេកមើលទៅខាងក្រោយ គឺក្នុងសម័យអតីតដែលទើបកន្លងទៅថ្មីៗ នេះនៅប្រទេសកម្ពុជាយើង ក៏គង់ជ្រាបបានក្នុងបញ្ហានេះ ឯក្នុងលោកនេះយើងអាចសន្និដ្ឋានថា អ្នកនោះផុតពីទុក្ខទោសបានមែន ប៉ុន្តែទៅក្នុងលោកខាងមុខប្រាកដជាពុំផុតឡើយ ។

ព្រះពុទ្ធវង្ស គឹម - ទូរ

វត្តឧណ្ណាលោម

ឆ្លើយដោះស្រាយតាមសេចក្តីតម្រូវរបស់

លោកប្រធាននៃក្រុមអ្នកនិពន្ធទស្សនាវដ្តី ពន្លឺពុទ្ធចក្រ



# ប្រវត្តិសង្ខេបនៃនាង យ៉ាន (១)

នាងនេះ សព្វថ្ងៃអាយុ ១៣ ឆ្នាំ កើតនៅភូមិ-ឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ដែលបានដឹងកំណើតរបស់ខ្លួនយ៉ាងជាក់ច្បាស់, មានរូបភាពដូចអស់លោក-អ្នកឃើញនេះស្រាប់ ។

ដើមដំបូង, នាងនៅភូមិកំពង់បឹង ឃុំមៀន ស្រុកកោះសុទិន ខេត្តកំពង់ចាម, មានកូនប្រុស ១, កូនស្រី ១ ហើយនាងស្លាប់ទៅក្នុងអាយុ ២៤ ឆ្នាំដោយជម្ងឺគ្រុនក្ដៅ ។ កាលដែលនាងស្លាប់នោះ បានទៅកើតនៅអាស្រ័យលើដើមឈើអស់រយៈកាលចំនួន ១០ ឆ្នាំ មានម្ដាយថែរក្សា មានការរស់នៅដូចធម្មតា ហាក់ដូចជាគ្មានថ្ងៃគ្មានយប់ទេ មានពន្លឺភ្លឺជានិច្ច ។ បើនាងចង់បរិភោគរបស់អ្វី របស់នោះតែងអណ្ដែតមកជិតនាង ហើយនាងក៏បរិភោគវត្ថុនោះៗទៅ ។ បើមានភ្លៀងមួយដងមួយកាលមក ជួនកាលនាងក៏ទៅជ្រកក្រោមសាលាឬក្រោមកុដិភិក្ខុសង្ឃ, បើមានមនុស្សណាទៅកាប់ដើមឈើដែលនាងនៅ នាងក៏ថយចេញទៅនៅទីដទៃទៀត ឥតមានទោមនស្សអ្វីទៅនឹងគេទេ មានសេចក្ដីគោរពខ្លាចមនុស្សជានិច្ច ។ កាលណា មានបងប្អូនធ្វើបុណ្យ ហើយគេហៅគេឲ្យទៅបរិភោគភោជនាហារ នាងក៏ទៅបរិភោគជួបជុំជាមួយនឹងញាតិមិត្រ បានឃើញភិក្ខុសង្ឃគង់នៅទីនោះដែរ តែហាក់ដូចជាពុំនឹកនាថានឹងថ្វាយបង្គំលោកសោះ ។ កាលដែលនាងកើតនៅលើដើមឈើនោះ មានពួកខ្លះគ្មានអាហារបរិភោគទេ ឃើញទៅបេះស្លឹកឈើខ្លះ ស្លឹកប្រិចខ្លះបរិភោគ ។ ថ្ងៃមួយម្ដាយរបស់នាងដែលនៅជាមួយនោះប្រាប់ថា ឯងទៅកើតជាមនុស្សវិញចុះ ។ នាងក៏ដើរចេញពីទីនោះទៅ ឃើញម្ដាយរបស់ខ្លួនសព្វថ្ងៃកំពុងច្រូតស្រូវ, នាងក៏ចូលទៅចាប់បដិសន្ធិនឹងម្ដាយនោះ ។ លុះកើតឡើងបានអាយុ ៣ ឆ្នាំ នាងបាននិយាយប្រាប់ឪពុកម្ដាយថាខ្លួនពីដើម នៅភូមិកំពង់បឹង ឃុំមៀន ស្រុកកោះសុទិន ខេត្តកំពង់ចាម ជាអ្នកមានទ្រព្យសម្បត្តិបង្គួរដែរ មានប្ដីហើយមានទាំងកូន ២ ទៀតផង ។ ខណៈនោះនាងនិយាយប្រាប់ដោយសំដីពុំសូវច្បាស់លាស់តាមភាពជាកុមារតូចនៅឡើយ ។ ឪពុកម្ដាយរបស់នាងព្រួយខ្លោះ ដោយខ្លាចក្រែងកូននិយាយតទៅ

១) ហៅនាង យ៉ាន នេះជាឈ្មោះកំណើតដើម ឯឈ្មោះកំណើតសព្វថ្ងៃហៅនាង សុខុម ។

ទៀត ក៏រកឧបាយផ្សេងៗ មានយកស៊ុតមាន់ចាំសំបុកនឹងគោសរីកជាដើមផ្សំធ្វើឲ្យនាងបរិភោគ ដើម្បីបំភ្លេចចោលនូវការដឹងជាតិកំណើតរបស់នាង ប៉ុន្តែការធ្វើនោះពុំបានលទ្ធផលអ្វីទេ នាងនៅតែចាំជាតិដដែលឥតភ្លេចឡើយ ។ គន្លងកាលមកនាងបានអាយុ ១០ ឆ្នាំ មានអ្នកភូមិព្រៃដើមចិនទៅទិញជ្រូកផ្សេងៗ ឯភូមិកំពង់ចិន នាងក៏រត់តាមគេទៅ លុះទៅដល់ទីភូមិផ្ទះរបស់ខ្លួនពីដើមហើយ ក៏ដើរចូលទៅដោយគ្មានអ្នកណាដឹកនាំ នាងនិយាយទៅរកបងប្អូនរបស់នាងដែលមានវ័យចាស់ៗ ណាស់ទៅហើយ ហាក់ដូចជានាងមានវ័យស្មើៗគ្នា ។ គេក៏បានពិសោធបញ្ជាក់ដោយហេតុផ្សេងៗ មានយករបស់ទ្រព្យនេះខ្លះនោះខ្លះ ជារបស់ធ្លាប់មានក្នុងជំនាន់ដែលនាងរស់នៅពីដើមនោះ មកសាកសួរ នាងក៏ឆ្លើយប្រាប់គេសព្វគ្រប់ឥតខុស ឃើញថានាងនេះពិតជាដឹងជាតិកំណើតរបស់ខ្លួនមែន ។

លុះគន្លងទៅបានអាយុ ១៣ ឆ្នាំ នាងមកភ្នំពេញដើម្បីសួររកកូនប្រុសរបស់ខ្លួនពីដើមដែលមកនៅភ្នំពេញ ចំណែកខាងគហបតី បេ-យាន ដែលត្រូវជាមារបស់នាងពីមុនបានដឹងដូច្នោះហើយ ក៏ហៅនាំនាងចូលទៅផ្ទះ ហើយបានសួរពិសោធសព្វបែបយ៉ាងទៅ នាងក៏ឆ្លើយប្រាប់យ៉ាងនេះយ៉ាងនោះដោយសព្វគ្រប់ តាមដែលខ្លួនដឹង ទើបគហបតី បេ-យាន សន្និដ្ឋានថា នាង យ៉ាន នេះ បានដឹងជាតិកំណើតរបស់ខ្លួនប្រាកដមែន ។

គហបតី បេ-យាន បានមានប្រសាសន៍ថា ដំណើររបស់នាង យ៉ាន ដែលដឹងជាតិនោះ គឺដឹងប្រហែលគ្នានឹងមនុស្សដែលមានវ័យប្រមាណជា ១៥ ឆ្នាំ ឬ ២០ ឆ្នាំ ហើយឃ្លាតចេញអំពីជាតិភូមិរបស់ខ្លួន ទៅនៅទីដទៃឆ្ងាយអស់កាលដ៏យូរប្រហែលជា ១០ ឆ្នាំ ឬ ១៥ ឆ្នាំ ហើយត្រឡប់មកវិញ នៅមានការដឹងចាំយ៉ាងណា នាងនេះក៏នៅដឹងចាំបានដូច្នោះដែរ ថ្វីបើនាងស្លាប់ពីមនុស្សទៅកើតនៅលើដើមឈើ អស់រយៈកាល ១០ ឆ្នាំ ហើយច្យុតពីដើមឈើនោះមកកើតជាមនុស្សនេះទៀត ក៏នៅតែដឹងចាំជាតិរបស់ខ្លួនមិនភ្លេចបាត់ ។

អាកប្បកិរិយារបស់នាង យ៉ាន នេះចំឡែកគួរឲ្យអស្ចារ្យណាស់ មិនសមជាក្មេងស្រីត្រឹមអាយុ ១៣ ឆ្នាំទេ ពីព្រោះនាងនេះមានបុកគាសណ្ដាប់ធ្នាប់ ព្រមទាំងសំដីនិយាយភាពដូចជាមនុស្សចាស់ទុំ, ជួនកាលបើនាងទៅជួបនឹងកូន ឬ ប្អូនរបស់ខ្លួនពីដើមដែលគេមានវ័យចាស់ៗ ហើយ ក៏នៅតែហៅគេដោយចំៗ ឈ្មោះថា អា-(នេះ), មេ (នេះ) ឯកូន ឬ ប្អូនទាំងនោះក៏ជឿទទួលគោរពសំគាល់ថាជាម្ដាយ ឬ បងរបស់ខ្លួនទៅហើយ ។ ឥឡូវនាងនេះត្រូវជាឪពុករបស់ខ្លួនពីដើមមានអាយុ ៧០ ប៉ាយឆ្នាំហើយនៅផ្សារអូរាំងឪ មានជម្ងឺដោយរោគជរា ក៏ទៅនៅបំរើឪពុកដើមឯផ្សារអូរាំងឪសព្វថ្ងៃនេះ ។ នាងនៅមើលថែទាំត្រួតត្រាហែហមបន្ដាប់បញ្ជាយ៉ាងស្និទ្ធ

ទៅលើកូននឹងប្ដីឲ្យធ្វើកិច្ចដូច្នេះដូច្នោះ ហាក់ដូចខ្លួននៅជាម្ដាយ ឬបងគេពីដើមដដែល ។

ប្រវត្តិគឺរឿងរ៉ាវរបស់នាង យ៉ាន នេះ មានសេចក្ដីផ្សេងទៀតនៅសល់ច្រើនណាស់ ដែលស្រង់យកមកសរសេរចុះក្នុងសៀវភៅនេះជាសេចក្ដីបំព្រួញខ្លីពេក បើអស់លោក-បងជ្រាបច្បាស់លាស់ច្រើនជាងនេះ សូមអញ្ជើញទៅសួរគហបតី បេ-យាន នៅក្រុងកំពេញជាមានៃនាងនេះពីដើម ព្រោះបានជួបប្រាស្រ័យផ្ទាល់ជាមួយនឹងនាងនេះ ឬ អញ្ជើញទៅមើលសួរផ្ទាល់ខ្លួននាង យ៉ាន នោះដល់ទីលំនៅក៏បាន ។

រឿងនេះតាមសេចក្ដីដែលមាននិយាយខ្លះក្នុងគម្ពីរខាងព្រះពុទ្ធសាសនា គេអាចយល់បានថា នាងនេះកាលដែលស្លាប់ពីមនុស្សហើយទៅកើតនៅនឹងដើមឈើនោះ គឺពិតជារុក្ខទេវតា ពីព្រោះពួកទេវតាដែលនៅឋានក្រោមខាងអាយនេះមានច្រើនប្រភេទគឺ ទេវតាណាដែលនៅអាស្រ័យនឹងភូមិ ឬ ផ្ទះជាលំនៅរបស់មនុស្ស ទេវតានោះហៅថា វត្ថុទេវតា, ទេវតាណាដែលនៅអាស្រ័យផ្ទាល់នឹងផែនដី ទេវតានោះហៅថា ភូមដ្ឋទេវតា, ទេវតាណាដែលនៅអាស្រ័យនឹងដើមឈើ ទេវតានោះហៅថា រុក្ខទេវតា, ទេវតាណាដែលនៅអាស្រ័យនឹងអាកាស ទេវតានោះហៅថា អាកាសដ្ឋទេវតា; ពួកនេះអាស្រ័យដោយបុញ្ញកម្មដ៏ស្ដួចស្ដើង ទើបទៅកើតជាទេវតាអស់នេះ ៗ មានអបាយសត្វមួយពួកទៀតថ្នាក់ថយថោកជាងនេះ អាស្រ័យដោយបាបកម្ម ហៅថា អសុរកាយៗ នេះកើតនៅអាស្រ័យនឹងផែនដី មានគ្រឿងស្មោកគ្រោកគ្រឿងសំអុយជាអាហារ ។

រឿងដូចខាងលើនេះ ស្របគ្នានឹងពាក្យនៃពុទ្ធសាសន៍ថា “កម្មស្សកា ពួកសត្វមានកម្មគឺអំពើល្អនឹងអាក្រក់ជារបស់ខ្លួន, កម្មយោនី ពួកសត្វមានកម្មជាកំណើត សត្វដែលបានទទួលសុខ-ទុក្ខ, ល្អ-អាក្រក់ ព្រោះតែកម្ម” ។ ពាក្យនេះឃើញថាផ្ទុយគ្នាស្រឡះពីពាក្យនៃអ្នកសស្សតទិដ្ឋិ ដែលគេយល់ថាសត្វមានគតិទៀងទាត់ ធ្លាប់កើតជាជាតិអ្វីហើយដល់ស្លាប់ទៅវិញ ក៏ទៅកើតជាជាតិនោះដដែលវិញឥតផ្លាស់ប្ដូរ ឬ អ្នកឧច្ឆេទទិដ្ឋិ ដែលគេយល់ថាសត្វដែលកើតមកហើយ ដល់ស្លាប់ទៅវិញសូន្យឈឹងតែម្ដង ឥតមានទៅកើតជាអ្វីទៀតទេ, សេចក្ដីល្អនឹងអាក្រក់ ឬ សុខនឹងទុក្ខ កើតឡើងឯង ៗ ម្ល៉ោះហើយបានជាពួកនេះ ហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ដោយឥតគោតញញើត ។

មួយយ៉ាងទៀត ភទៈនៃពុទ្ធសាសន៍ថា កម្មជាចំណងដ៏មាំសម្រាប់ចងក្រៀកសត្វឲ្យត្រាច់រង្គាត់កើតស្លាប់នៅតែក្នុងវដ្តសង្សារឥតឈប់ឈរ លុះតែសត្វនោះអស់កម្មត្រឹមណា ទើបឈប់កើតត្រឹមនោះ ។

ព្រះពុទ្ធវង្ស ភឹម - ទូរ

វត្តឧណ្ណាលោម

រៀបរៀង

តាមសេចក្ដីឲ្យការអំពីគហបតី ប៊េ - យ៉ាង

# សមាជទី ៦ នៃពុទ្ធិកសមាគមពិភពលោក

នៅខែវិច្ឆិកា គ.ស. ១៩៦១ មាន ៤៤ ប្រទេសកាន់ពុទ្ធសាសនា នឹងមករួមប្រជុំជាសមាជ នៅកម្ពុជរដ្ឋ

ព្រះរាជអាណាចក្រកម្ពុជា

លេខ ១៦៤៦

ចុះថ្ងៃទី ២៦-៩-៦១

គណៈរដ្ឋមន្ត្រី

ប្រកាសក្រសួង

នាយករដ្ឋមន្ត្រី ស្ដីទី

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជអាណាចក្រ ។

បានឃើញព្រះរាជក្រឹត្យលេខ ៨-ប-រ-ចុះថ្ងៃទី ២៨ មករា ១៩៦១ ស្ដីពីការតែងតាំងគណៈរដ្ឋមន្ត្រី កែប្រែតាមព្រះរាជក្រឹត្យលេខ ៤៩-ប-រ ចុះថ្ងៃទី ១១ មីនា ១៩៦១ ស្ដីពីការកែប្រែសមាសភាព នៃគណៈរដ្ឋមន្ត្រីនេះ ។

បានឃើញព្រះរាជក្រឹត្យលេខ ៩-ប-រ ចុះថ្ងៃទី ២៨ ខែមករា គ.ស. ១៩៦១ ស្ដីអំពីព្រះរាជានុញ្ញាតប្រគល់ចំពោះរដ្ឋមន្ត្រីទី ១ នូវសិទ្ធិចុះហត្ថលេខាអមលើព្រះរាជក្រម ព្រះរាជក្រឹត្យទាំងអស់ក្នុងនាមនៃនាយករដ្ឋាភិបាល ។

បានឃើញព្រះរាជក្រឹត្យលេខ ១៤២-ប.រ ចុះថ្ងៃទី ១៣ ឧសភា ១៩៦១ ស្ដីអំពីការតែងតាំងលោកទេព-ផន ជានាយករដ្ឋមន្ត្រីស្ដីទី ។

បានឃើញលក្ខន្តិកៈ នៃពុទ្ធិកសមាគមពិភពលោកដែលសន្និសីទលើកទី ១ នៃទីក្រុងកូឡុំបូ "ប្រទេសស៊ីឡង់" បានសម្រេចពីថ្ងៃទី ៦ មិថុនា ១៩៥០ ។

បានឃើញសេចក្ដីកត់ហេតុមហាសន្និបាត នៃគណៈរដ្ឋមន្ត្រីពីថ្ងៃទី ១៧ មីនា ១៩៦១ យល់ព្រមឲ្យរៀបចំសមាជលើកទី ៦ នៃពុទ្ធសាសនាសាកលលោកនៅប្រទេសកម្ពុជាក្នុងខែវិច្ឆិកា ១៩៦១ ។

ដោយសេចក្ដីស្នើ នៃរដ្ឋមន្ត្រីក្រសួងធម្មការ ៖

## សម្រេចដូចខាងក្រោម ៖

ប្រការ ១– បានស្ថាបនានូវគណៈកម្មាធិការមួយនាមថា ៖ គណៈកម្មាធិការសម្រាប់ចាត់ចែងការរៀបចំសមាជលើកទី ៦ នៃពុទ្ធសាសនាសាកលក្នុងឆ្នាំ ១៩៦១ ។ គណៈកម្មាធិការនេះមានសមាសភាពដូចតទៅ ៖

១ – រដ្ឋមន្ត្រីទី ១ រដ្ឋមន្ត្រីក្រសួងឆ្មការ ឬតំណាង . . . . . . . . ប្រធាន

២ – ទេសរដ្ឋមន្ត្រី ទទួលភារៈខាងក្រសួងការបរទេស . . . . . អនុប្រធានទី ១

៣ – រដ្ឋលេខាធិការក្រសួងធម្មការ . . . . . . . . . . អនុប្រធានទី ២

៤ – តំណាងអគ្គនាយកដ្ឋានក្នុងព្រះបរមរាជវាំង . . . . . . . . សមាជិក

៥ – សម្តេចព្រះសង្ឃនាយកគណៈមហានិកាយ ឬតំណាង . . . . . . . . ដ –

៦ – សម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិ ឬតំណាង . . . . . . . . ដ –

៧ – ព្រះពោធិវង្សអគ្គាធិការពុទ្ធិកសិក្សា ឬតំណាង . . . . . . . . . ដ –

៨ – តំណាងប្រធានរដ្ឋសភា . . . . . . . . . . . . . . ដ –

៩ – តំណាងប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ . . . . . . . . . ដ –

១០ – អ្នកឧកញ៉ា ទេសរដ្ឋមន្ត្រីទទួលភារៈខាងក្រសួងការពារប្រទេស ឬតំណាង . . ដ –

១១ – អ្នកឧកញ៉ា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង . . . . . ដ –

១២ – អ្នកឧកញ៉ា ទេសរដ្ឋមន្ត្រីទទួលភារៈខាងក្រសួងមហាផ្ទៃ ឬតំណាង . . . ដ –

១៣ – អ្នកឧកញ៉ា រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ឬតំណាង . . . . . . . . ដ –

១៤ – អ្នកឧកញ៉ា រដ្ឋមន្ត្រីក្រសួងសាធារណការ ឬតំណាង . . . . . . . ដ –

១៥ – អ្នកឧកញ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ ឬតំណាង . . . . ដ –

១៦ – អ្នកឧកញ៉ា រដ្ឋមន្ត្រីក្រសួងការងារនិងសង្គមកិច្ច ឬតំណាង . . . . . ដ –

១៧ – អ្នកឧកញ៉ា រដ្ឋមន្ត្រីក្រសួងឃោសនាការ ឬតំណាង . . . . . . . ដ –

១៨ – អ្នកឧកញ៉ា រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ឬតំណាង . . . . . . . . ដ –

១៩ – អ្នកឧកញ៉ា រដ្ឋលេខាធិការទទួលភារៈខាងសន្តិសុខជាតិ និងការពារលើផ្ទៃប្រទេស
ឬតំណាង . . . . . ដ –

២០ – នាយកប្រតិភូនៃរដ្ឋាភិបាលទទួលភារៈខាងនាយកដ្ឋានទេសចរ . . . . . ដ –

២១ – តំណាងនៃគជប្រតិភូប្រចាំក្រុងភ្នំពេញ . . . . . . . . . . ដ –

២២ – ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យ . . . . . . . . . . ដ –

២៣ – ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ សមាជិក

២៤ – ប្រធានសមាគមគិលានុបដ្ឋានព្រះមហាក្សត្រិយានី ដ

២៥ – អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ដ

២៦ – អគ្គលេខាធិការពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ដ

២៧ – នាយខុទ្ទកាល័យក្រសួងធម្មការ ដ

២៨ – លោក មៃរ - ប៉ាន់ នាយការិយាល័យធម្មការ លេខាធិការ

២៩ – លោក ឌី - រ៉ង លេខាធិការការិយាល័យធម្មការ –

៣០ – " ចាប - ប៊ិន – –

៣១ – " អៀង - គិម – –

៣២ – " ខៀវ - ព្រីង – –

ប្រការ ២ - គណៈកម្មាធិការនេះនឹងមានបេសកកម្ម :

១ – ១ ស្តាប់នានូវសេចក្តីព្រាងថវិកាចំណាយ

១ – ២ រៀបចំធ្វើកម្មវិធីនៃសមាជ

១ – ៣ ចាត់តាំងគណៈកម្មការរៀបចំសមាជនេះ ខាងគ្រឿងសម្ភារៈ

គណៈកម្មការនេះនឹងត្រូវប្រជុំតាមសេចក្តីអញ្ជើញ នៃប្រធាន ។

ប្រការ ៣ - រដ្ឋលេខាធិការក្រសួងធម្មការនឹងអគ្គលេខាធិការនៃមន្ទីរនាយករដ្ឋមន្ត្រីត្រូវទទួលភារៈ ចាត់ការឲ្យបានសម្រេចរៀងៗខ្លួនតាមប្រការនេះ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា គ.ស. ១៩៦១

ហត្ថលេខា : ឌេ៣-ដង

ឯ ៤៤ ប្រទេសនោះ មានបញ្ជីរាយតាមខាងក្រោមនេះស្រាប់គឺ ៖

1— Assam អស្សាម

2— Autriche អូទ្រីស

3— Angleterre អង់គ្លេស

| | |
|---|---|
| 4— Allemagne Ouest | អាល្លឺម៉ង់ខាងលិច |
| 5— Allemagne Est | អាល្លឺម៉ង់ ខាងកើត |
| 6— Australie | អូស្ត្រាលី |
| 7— Birmanie | ភូមា |
| 8— Bhutan | ភូតាន |
| 9— Ceylan | ស្រីលង្កា |
| 10— Cambodge | កម្ពុជា |
| 11— Corée du Nord | កូរ៉េខាងជើង |
| 12— Corée du Sud | កូរ៉េខាងត្បូង |
| 13— Canada | កាណាដា |
| 14— Danemark | ដាណឺម៉ាក |
| 15— Estonie | អេស្តូនី |
| 16— France | បារាំង |
| 17— Finlande | ហ្វាំងឡង់ |
| 18— Hongrie | ហុងគ្រី |
| 19 – Hawai | ហាវ៉ៃ |
| 20— Hong—Kong ( Macao ) | ហុងកុង (ម៉ាកៅ) |
| 21— Inde | ឥណ្ឌៀ |
| 22— Italie | ឥតាលី |
| 23— Indonésie | ឥណ្ឌូនេស៊ី |
| 24— Iles Philippines | ហ្វីលីពីន |
| 25— Japon | ជប៉ុន |
| 26— Laos | ឡាវ |

| | |
|---|---|
| 27— Lituanie | លីតូអានី |
| 28— Lettonie | ឡែតតូនី |
| 29— Mongolie | ម៉ុងហ្គោលី |
| 30— Malaisie | ម៉ាឡាយូ |
| 31— Népal | នេប៉ាល |
| 32— Norvège | ណូវ៉ែស |
| 33— Nouvelle Zélande | នូវែលហ្សេឡង់ |
| 34— Pakistan (Est) | ប៉ាគិស្ថានខាងជើង |
| 35— République de la Chine Populaire | ចិនប្រជាមានិត |
| 36— Sikkim | ស៊ិកគីម |
| 37— Singapore | សង្គបូរ |
| 38— Suède | ស៊ុយអែត |
| 39— Thailande | សៀម |
| 40— Tchécoslovaquie | ចេកូស្លូវ៉ាគី |
| 41— U.S.A. | សហរដ្ឋអាមេរិក |
| 42— U.R.S.S. | សហភាពរុស្សី |
| 43— Vietnam—Nord | វៀតណាមខាងជើង |
| 44— Vietnam—Sud | វៀតណាមខាងត្បូង |

# អំពីនាមអស់លោកដែលបានសុំចូលជា
# សមាជិកសមាជិកានៃ ឧ.ម.ភ. ក្នុងឆ្នាំ ១៩៦១

(គិតពីថ្ងៃទី ១ មករា ទៅទល់ថ្ងៃទី ១ មិថុនា ១៩៦១)

ក – ផ្នែកសមាជិកសមាជិកាដែលបានយកចិត្តទុកដាក់ខ្វល់ខ្វាយជាញឹកញាប់ជួយឲ្យសមាគមយើងបានចំរើន មានជួយច្រើនរំលឹកទីជួយទារប្រាក់ភាគទានអំពីសមាជិកសមាជិកាជាដើមគឺ :

| | | |
|---|---|---|
| ១ – លោកស្រី | ដោក-ស៊ីដេត | ក្រុងភ្នំពេញ |
| ២ – លោក | យង់-ប៊ិន | ក្រុមព្រះនគរបាលជាតិ |
| ៣ – " | ហ៊ីង-រុណ | នាយក្រុមសង្គមកិច្ចកងអយស្ម័យយាន |
| ៤ – " | ខៀវ-សន | – " – |
| ៥ – " | ម៉ី-សារិន | ផ្នែកពេជចក្រ – " – |
| ៦ – " | ប៊ិន-ឈឹមសួន | សុរិយោដីក្រុង |
| ៧ – " | មាស-ហាំ | សាលាក្រុង |
| ៨ – " | ខោល-ថៃ | លេខាធិការដ្ឋានផ្ទាល់សម្តេចព្រះប្រមុខរដ្ឋ |
| ៩ – " | អ៊ី-អេង | ពេទ្យមិត្តភាពខ្មែរ-សូវៀត |

ខ – ផ្នែកធ្វើអំណោយជាពិសេសគឺ :

១ – គហបតី គី-ហុកហ៊ួរ អ្នកស្រី អ៊ឹង-ផេងណៃ ធ្វើអំណោយពិសេស ២.០០០៛០០ អំណោយប្រចាំខែ ៥០៛០០

| | | | | |
|---|---|---|---|---|
| ២ – ឃុនទេពកញ្ញាសោភា | គិម-អានយាប | – " – | ១.០០០៛០០ | – ១០៛០០ |
| ៣ – លោកស្រី | ប៊ុន-ចន្ទបុប្ផា | . . . . . . . . . . – | | ១០០៛០០ |
| ៤ – " | តាន់-ឈុនហ៊ាង | . . . . . . . . . . – | | ១០០៛០០ |
| ៥ – " | ដុស-ជួង | . . . . . . . . . . – | | ១០០៛០០ |
| ៦ – លោក | សារុន-ឯម | . . . . . . . . . . – | | ៥០៛០០ |
| ៧ – " | អ៊ុក-សាន | . . . . . . . . . . – | | ៥០៛០០ |
| ៨ – លោកស្រី | ស្រី-សម | . . . . . . . . . . – | | ៣០៛០០ |
| ៩ – " | តាន់-ជិនហុក | . . . . . . . . . . – | | ២០៛០០ |

១០– លោកស្រី ប៉ោ-គី យ៉េហោហៀប វ៉េង . . . . . . . . . . – ២០.០០

១១– „ គឹម-ហុង . . . . . . . . . . . . – ២០.០០

គ – ផ្នែកបង់ភាគទានជាកម្មិកសមាជិកគឺ :

| | | | |
|---|---|---|---|
| ១ – | លោក | អ៊ុក-ឌី | សាលាសន្សំសុខ |
| ២ – | „ | ពាច-ខាន់ហៅង៉ាន់ | „ |
| ៣ – | លោក | ទុ-អុន | „ |
| ៤ – | „ | សោម-ជាំ | „ |
| ៥ – | លោកស្រី | ស៊ឹម-ប៉ាត | „ |
| ៦ – | „ | អ៊ុក-ឌី | „ |
| ៧ – | លោកវេជ្ជបណ្ឌិត | ថោ-ប៉េងថុង | ក្រុងភ្នំពេញ |
| ៨ – | „ | ឡេង-ឈុំ | សាធារណការ |
| ៩ – | „ | ង៉ួន-ថៃ | បរិស័ទធូរបូពិធានាជីវិត |
| ១០ – | „ | អ៊ុង-អៀង | នគរបាលជាតិ |
| ១១ – | „ | ទី-ប៊ុនហេង | កំពង់ចាមក្រុង |
| ១២ – | „ | ហ៊ី-ស៊ីវ | ក្រុងភ្នំពេញ |
| ១៣ – | „ | ស្នួស-តាំង | „ |
| ១៤ – | „ | ទេស-ញ៉ាវ | „ |
| ១៥ – | „ | ស៊ិន-ស្រេងឃុយ | បណ្ណាគារផ្សារចាស់ |
| ១៦ – | លោកចំពាវ | ស៊ិម-ហ៊ាង | ក្រុងភ្នំពេញ |
| ១៧ – | លោកស្រី | ពាយ-ធុល | „ |
| ១៨ – | „ | ថោង-ម៉ាមុត | „ |
| ១៩ – | „ | ប៊ិន-ឈឹមសួន | „ |
| ២០ – | „ | ហែម-សាវម៉ាវ | „ |

| | | |
|---|---|---|
| ២១ – ឧបាសិកា | ម៉ែត | ក្រុងភ្នំពេញ |
| ២២ – យីហៅ | ហាក់ - ឈាង | ” |
| ២៣ – លោក | ព្រហ្ម-វ៉ែនអ្នកស្រីសោម - ខិម | ” |
| ២៤ – ” ស្រី | ស្រី-សំណាង | ” |

## តម្លៃជាវ

| | |
|---|---|
| ១ ក្បាល | ២៥,០០ |
| ប្រចាំឆ្នាំ | ៩០,០០ |

ផ្ញើអាណត្តិប្រៃសណីយ៍ទៅ៖

លោក រស់-ហែម អគ្គហេរញ្ញិកនៃពុទ្ធិក-
សមាគមកម្ពុជរដ្ឋ នៅវត្តឧណ្ណាលោម ភ្នំពេញ

**Monsieur Ros-Hèm Trésorier**
**général de l'Association des Bouddhistes**
**au monastère d'Unnalom à Phnom-Penh**